ខ្មែរប៉ុស្ដិ៍
ផ្សេរខាងកើត
VOL. 05 ISSUE 71 NOV. 05th – 15th, 2010
KhmerPost USA
Printing The Cambodian World News
Philadelphia

មាតិការឿង **ទំព័រ**

១- លទ្ធផលនៃការបោះឆ្នោត............................០៣
២- កិច្ចសម្ភាសន៍រវាងខ្មែរប៉ុស្ដិ៍ ០៥
៣- រព្ញកថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣.....................០៧
៤- THE CAMBODIA DAILY .... ០៨ & ១៣
៥- ស្ត្រីខ្មែរដំបូងបង្អស់ដែលបានធ្វើដំណើរ................១០

ទស្សនកិច្ចរបស់អគ្គលេខាធិការនៃ អង្គការសហប្រជាជាតិនៅកម្ពុជា

លោក បាន គីមូន

ខ្មែរប៉ុស្ដិ៍ : លោក បាន គីមូន អគ្គលេខាធិការថ្មីរបស់ អ.ស.ប បានផ្ដើមទស្សនកិច្ច៣ថ្ងៃនៅកម្ពុជាពីថ្ងៃទី២៦ ខែតុលាមុននេះ ។ លោកបានទៅទស្សនាជាអាទិ៍នៅមន្ទីរពេទ្យរុស្ស៊ីផ្នែកសសៃប្រសាទ. ទស្សនាសាលាក្ដីតុលាការអន្តរជាតិ ហើយបានជួបពិភាក្សាជាមួយលោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន មុននឹងបន្តដំណើរទៅកាន់វៀតណាម ។

លោក ខៀវ កាញ្ញារីទ្ធ បាននាំពាក្យជំនួបរវាងលោក ហ៊ុន សែន និងលោក បាន គីមូន ថា : លោកអគ្គលេខាធិការ អ.ស.ប បានសុំអនុសាសន៍ពីលោក ហ៊ុន សែន នូវចំណុចមួយចំនួនដែលទាក់ទងនឹងការបន្តកាត់ក្ដីក្នុងបញ្ហាខ្មែរក្រហមក្នុងនោះ លោក ហ៊ុន ក៏មានបំណងឱ្យបញ្ចប់ក្ដីត្រឹមតែមេដឹកនាំសំខាន់ៗរបស់ខ្មែរក្រហមតែប៉ុណ្ណោះ រឿងនេះល្មមគ្រប់គ្រាន់ត្រឹមសំណុំរឿង០០១ និង០០២ ***(តទៅទំព័រទី ១៦)***

លោកស្រីរដ្ឋលេខាធិការក្រសួងបរទេសអាមេរិកាំងនៅកម្ពុជា

លោកស្រី ហ៊ីឡារី គ្លីនតុន

ខ្មែរប៉ុស្ដិ៍ : ទស្សនកិច្ចដ៏គួរឱ្យកត់សំគាល់ម្នាក់ទៀតនោះ គឺលោកស្រី ហ៊ីឡារី គ្លីនតុន រដ្ឋលេខាធិការនៃរដ្ឋាភិបាល អូបាម៉ា ក៏បានទៅទស្សនកិច្ចនៅកម្ពុជាដែរ ថ្ងៃទី៣០ ខែតុលានេះ ។ លោកស្រីបានទៅធ្វើទស្សនកិច្ចនៅអង្គរវត្ត នៃខេត្តសៀមរាប ហើយបានជួបប្រាស្រ័យទាក់ទងនឹងមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាលខ្មែរ ហើយនឹងចូលគាល់ព្រះមហាក្សត្រ នរោត្តម សីហមុនី ផងដែរ ។

នៅពេលជួបជាមួយលោកឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេសខ្មែរ លោក ហោ ណាំហុង លោកស្រីបានថ្លែងសរសើរពីការបញ្ជូនកងទ័ពខ្មែរឱ្យទៅចូលរួមដំណើរការសន្តិភាពនៅប្រទេសផ្សេងៗ ដែលញ៉ាំញីដោយសង្គ្រាមៗ ចំពោះការគោរពសិទ្ធិមនុស្សនៅកម្ពុជា លោកស្រីនិយាយថា "នឹងស្វែងរកជំនួយបន្ថែមទៀត ដើម្បីបន្ថែមការបណ្ដុះបណ្ដាល

(តទៅទំព័រទី ១៦)

Pipe Bomb scared in Lynn-suspects being questioned

KhmerPost USA writer: Audria Chea

October had been a scary month for the Lynners. Explosive devices were found in three different locations in Lynn. In one incident the neighborhood was being evacuated for the State Police Bomb Squad to detonate the bomb.

Ms. Thany Por, Lynn business owner shared, "It is scary. The community is not as safe anymore." Ms. Por learned of the bomb scared through reading the Lynn local Newspaper, Lynn Daily Item and had shared the news with other Cambodian Lynners, "but they don't seem to know anything about it or worry too much", she said.

The Explosive device first found on the Lynn and Swampscott line at 28 Hillside Avenue, on October 11. Mrs. Helen Toye, who has been a resident of Lynn and who has been living on Hillside Avenue for 50 years explained, "Hillside Avenue is very long. It runs through both Lynn and Swampscott." The incident happened on October 11 was on Swampscott side. Mrs. Toye observed there was a held back and people have to detour to different streets to get home.

(Continued to page 16)

លីន : នាខែតុលានោះ គ្រាប់បែកបានផ្ទុះបីដងបន្តបន្ទាប់គ្នានៅលីនរយៈពេលប្រមាណបីថ្ងៃម្ដង ។ ការផ្ទុះនេះមិនបណ្ដាលឱ្យមានអ្នករងរបួសទេ តែមនុស្សក្នុងតំបន់មានការភិតភ័យយ៉ាងខ្លាំង ។ គ្រាប់ទី១ផ្ទុះនៅ ២៨ ហ៊ីលសាយអាវិន្យូ នៅថ្ងៃទី១១ ខែតុលា គ្រាប់ទី២ផ្ទុះនៅលេខ៣ ផ្លូវ អេសិច រីឯគ្រាប់ទី៣ នៅថ្ងៃទី១៦ តុលា ផ្ទុះនៅលេខ ៨០ ផ្លូវខូលីន ។

អឌ្រា ជា ដែលបានតាមដាន ហើយរាយការណ៍ជាភាសាអង់គ្លេសនូវព្រឹត្តិការណ៍ដ៏គួរឱ្យព្រួយបារម្ភចំពោះសន្តិសុខគ្រួសារនេះថា "មេប៉ូលិស" ខេវិន "កំពុងតាមដាន ហើយចងជាឯកសារភស្តុតាងមួយចំនួនកំពុងត្រូវពិនិត្យ និងវិភាគនៅទីពិសោធន៍ឧក្រិដ្ឋកម្មនៃប៉ូលិសរដ្ឋរួចហើយ" ... ។ ***-ខ្មែរប៉ុស្ដិ៍-***

ពិភពលោករំញ្ជួយដោយសារសន្ធិសីទក្រុងប៉ារីសឆ្នាំ១៩៩១


ក្រុមបាតុករប្រមាណ ៤០០០នាក់នៅក្រុងប៉ារីស

សេចក្ដីប្រកាសរួមរបស់ពលរដ្ឋខ្មែរក្រៅប្រទេស
"មហាបាតុកម្មទូទាំងពិភពលោក ដើម្បីការពារបូរណភាពទឹកដី"
ទិវាសន្ធិសញ្ញាប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១

ក្រុងប៉ារីស ២៤ ខែតុលា ឆ្នាំ២០១០. ញូវយ៉ក ២២ ខែតុលា ឆ្នាំ២០១០. អ៊ុតាវ៉ា ២២ ខែតុលា ឆ្នាំ ២០១០ ទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ ២២ តុលា ២០១០។

ដោយយល់ឃើញថា ប្រទេសកម្ពុជា យើងបានទទួលរងការបាត់បង់ទឹកដី និងបន្តរំកិលព្រំដែននៃប្រទេសជជិតខាង មានសៀម យួន ទោះបីជាមានសន្ធិសញ្ញាជាលក្ខណៈអន្តរជាតិក៏ដោយ ។

ដោយយល់ឃើញថា ការចរចាទ្វេភាគីរវាងសៀម និងយួននោះ ខ្មែរយើងមិនបដែលបានទទួលលទ្ធផលប្រសើរក្រៅពីការ បាត់បង់ទឹកដីប៉ុណ្ណោះ ប្រវត្តិសាស្ត្រមានជាសក្ខីភាព ស្រាប់ ។

ដោយយល់ឃើញថា ទស្សនៈកិច្ចរបស់លោក បាន គីមូន អគ្គលេខាធិការនៃ អង្គការសហប្រជាជាតិ

(តទៅទំព័រទី ០៦)

សាលាសិក្សាពីការបង្រៀនកាត់សក់ ធ្វើក្រចក ថែរក្សាស្បែក លំអសម្ផស្ស ដាក់រោមភ្នែក
PHILADELPIA BEAUTY COSMETOLOGY SCHOOL
ចាប់បើកហើយ!
GRAND OPENING
សាលារៀនដែលធំជាងគេបង្អស់នៅក្នុងទីក្រុង !
ចំណុះសិស្សជាង២៥០នាក់ សាលាចាប់ផ្ដើមហើយ-សូមទូរស័ព្ទមកចុះឈ្មោះពីពេលនេះទៅរហូតដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ ដើម្បីឱ្យបានទទួល១០%ចុះថ្លៃបង់សាលារៀន
10% OFF TUTION
Expires 12/30/2010
OVER 250 STUDENTS CAPACITY.CLASS STARTS NOW.
CALL TO ENROLL
TODAY TO RECEIVE 10% OFF TUTION.
215-465-1614
តម្លៃពិសេស
- កាត់សក់បុរស $5
- កាត់សក់ស្ត្រី $7
- ដកចិញ្ចើម $4
- ថែរស្បែកមុខ $15
- Highlight សក់ $38* ទទួលបានការកាត់សក់ឥតយកថ្លៃ
- ធ្វើក្រចកដៃ + ជើង $18
- និងសេវាផ្សេងៗទៀត ដោយតម្លៃសមរម្យ

គ្រូបង្ហាត់មានបទពិសោធន៍ និយាយភាសាខ្មែរ
អង់គ្លេស វៀតណាម ចិន និង ស្ប៉ាញ៉ុល
711 SNYDER AVENUE. PHILADELPHIA, PA 19148
TEL. 215-465-1614 OR 215-609-7815, Fax: 215-465-1699

Stop N' Shop Discount Liquor

2305 Admiral Wilson Blvd., Camden, NJ 08105 ,Phone: (856) 365-4377 Fax: (856) 365-1342

REMY MARTIN

V.S.O.P. $35.99 750 ML.

XO $99.99 750 ML.

HENESSY V.O.S.P.

$39.99

750 ML.

MARTELL CORDON BLUE

$93.99

750 ML.

COURVOISIER XO

$99.99

750 ML.

ABSOLUT VOLKA

$18.09 750 ML.

$29.09 1.75 L.

Store Hours :

Mon. -Thurs.

9am - 10pm

Fri - Sat. 9am - Midnight

Sunday Noon - 10p.m

OPEN 365 DAYS



BEER :

Tsing Tao	12 Oz. 24 Loose Btls.	$23.99
Heineken	12 Oz. 24 Loose Btls.	$23.99
Corona	24 Loose Btls.	$23.99
"33" Export Vietnam		$29.99
Bud	12 Oz. Loose Btls.	$15.99
Sapporo	12 Oz. 24 Loose Btls.	$24.99

លទ្ធផលនៅការបោះឆ្នោត២០១០នៅរដ្ឋផេនស៊ីវេនា
Pennsylvania 2010 Election Results

By Sabane Thach

Novemeber 2nd was a tight race for America. Republication took control of the US House of Representative with 239 seats comparing to 183 seats for Democrat. However, the Democrat still remains majority in the U.S. Senate seats with 51 seats comparing to 46 seats for Republicans.

In Pennsylvania, celebration goes big for republican. Despite the President Barack Obama visited Pennsylvania three times in October to inspire voters to support Joe Sestak, plus the first lady one trip to empower voter participation at University of Pennsyl- vania on November 1st, the U.S. Senate Republican candidate Pat Toomey turned out 51% leaving Joe Sestak 49%.

PA Governor Candidates—The republican candidate Tom Corbett also won the election, he landed 55% comparing to 45% for Dan Onorator from Democrat party.



In Pennsylvania, the democrat also lost U.S. House of Representatives to republican. From District 7, Pat Meehan (R) came out 55%, Bryan Lentz (D) 44%

To District 8, Mike Fitzpatrick (R) turned out 54% and Patrick Muphy (D) 47%



215-383-6108
WWW.KAYLIMPHOTOGRAPHY.COM

YOO´S AUTO SERVICE AND BODY

អបអរសាទរខួបឆ្នាំទី២០
នៃផ្នែកជួសជុលរថយន្ត និងខួបទី១នៃផ្នែកគ្រឿងបន្លាស់

សេវាជួសជុល យូ អរគុណដល់អតិថិជន
ដែលបានគាំទ្រយើងតាំងពី២០ឆ្នាំមក

ពីព្រោះតែមានការគាំទ្រចំនួន២០ឆ្នាំមកហើយនោះ យើងខ្ញុំ និង សងគុណដោយបញ្ចុះថ្លៃជូនអតិថិជនទាំងអស់វិញ នាខួប២០ឆ្នាំ របស់សេវាជួសជុលរថយន្ត យូ ។
សូមពិនិត្យមើលតារាងខាងស្តាំ

Combo 1	Oil Change and Filter Free Tire Rotation (Regular 5W-30 Oil Only UP TO 5Q)	$19.95 +Tax
Combo 2	State Safty Inspection State Emissions Inspection	$39.95 +Tax
Combo 3	Oil Change and Filter Tire Rotation State Safty Inspection State Emissions Inspection	$55.95 +Tax

Combo 1, 2 and 3 Includes Free Visual Inspection

Belts, Hoses, Airfilter, Transmission Fluid, Engine Oil, Power Steering Fluid, Brakefluid, Antifreeze, Windshield Washer Fluid, Windshield Wiper, Brake Pads, Brake Shoes, Tires, Tire Air Pressure, Shocks, Struts, Front end Check, Exhaust System and More

TEL.(215)457-7777/7779 FAX.(215)457-7475
189W. Duncannon Ave., Phila, PA 19120

ទទួលថតវីឌីអូ និងរូបថតសន្លឹក
ស្អាត់ជំនាញផ្នែក អាពាហ៍ពិពាហ៍
ខួបកំណើត បុណ្យទាន និង ពិធីផ្សេងៗ
ទទួលកាត់តវីឌីអូ កាភអូខេ
ទទួលប្តូរប្រព័ន្ធ PAL ទៅ NTSC
ទទួលថតសំរាប់ផ្សាយពាណិជ្ជកម្ម

មានបទពិសោធន៍ជាង ២០ឆ្នាំ
ធានាគុណភាពល្អបំផុត
ពានលទ្ធផលយ៉ាងឆាប់រហ័ស

CLICKS STUDIO

Video & Photography

267-506-8639

សូមទាក់ទង:

ពិសិដ្ឋ	410-940-9338
សុភាព	267-767-2655
សួន	267-253-9302
ចំរើន	267-632-4768

Kavei Band

កាវីតន្ត្រី

កិច្ចសម្ភាសន៍រវាងខ្មែរប៉ុស្តិ៍ជាមួយប្រធានសមាគមអតីតយុទ្ធជនខ្មែរ

ដោយ : អ៊ឹម លឿម

•••ក្នុងឱកាសលោកប្រធានាធិបតីអាមេរិក បារ៉ាក់ អូបាម៉ា អញ្ជើញមកបំពេញទស្សនកិច្ចការងារនាទីក្រុងហ្វីឡាដែលហ្វៀ នាពេលថ្មីៗ កន្លងមកនេះ "ខ្មែរប៉ុស្តិ៍" ក៏ត្រូវបានផ្តល់កិត្តិយសទៅយកព័ត៌មានក្នុងជំនួបដ៏កម្រនោះដែរ តាមរយៈការអញ្ជើញពីសំណាក់ "សមាគមអតីតយុទ្ធជនខ្មែរ" ដែលប្រធានសមាគមនេះបានអះអាងថា ត្រូវបានអញ្ជើញពិសេសពីសេតវិមាន (White House) ដើម្បីឱ្យរដ្ឋាភិបាលសហរដ្ឋអាមេរិកទទួលស្គាល់ជាផ្លូវការ ។

ប៉ុន្តែជាអកុសលបំណងនៃការជួបប្រធានាធិបតីដ៏មានឥទ្ធិពលនេះត្រូវបានខកខានបណ្តាលមកពីការយឺតយ៉ាវក្នុងការធ្វើដំណើរ ។

ឆ្លៀតពេលនេះ "ខ្មែរប៉ុស្តិ៍" ក៏ត្រូវបានសម្ភាសន៍ជាមួយលោក សិរិទ្ធ ប៉ែន ជាឧត្តមសេនីយទោ ស្តីពីដំណើររឿងនានាជុំវិញសមាគមអតីតយុទ្ធជនខ្មែររបស់លោក :

អ៊ឹម លឿម : ថ្ងៃនេះជាថ្ងៃពិសេសមួយ គឺថ្ងៃទី១០ ខែតុលា ឆ្នាំ២០១០ ហើយជាថ្ងៃដែលលោកអូបាម៉ា អញ្ជើញមកកាន់ទីក្រុងហ្វីឡាដែលហ្វៀយើងនេះ តើខាងសមាគមអតីតយុទ្ធជនខ្មែររបស់លោកទៅជួបលោក អូបាម៉ា គឺមានបំណងផ្តោតសំខាន់ទៅលើអ្វីបាទ? ។

សិរិទ្ធ ប៉ែន : បាទគឺគោលបំណងរបស់សមាគមអតីតយុទ្ធជនខ្មែរ ទៅជួបលោក បារ៉ាក់ អូបាម៉ា នេះគឺចង់ឱ្យរដ្ឋាភិបាលសហរដ្ឋអាមេរិក បានទទួលស្គាល់និងដឹងឮថា សមាគមអតីតយុទ្ធជនខ្មែរយើងនេះកើតឡើងពីខែ៥ ថ្ងៃទី២ ឆ្នាំ២០១០ ហើយរហូតមកដល់ឥឡូវនេះ មានអាយុនៅក្មេងខ្ចី ។ ដូច្នេះហើយយើងចង់រៀបចំឱ្យក្មេងជំនាន់ក្រោយឱ្យធ្វើកិច្ចការសម្រាប់ជួយអតីតយុទ្ធជនខ្មែរ ដែលពួកគាត់មានអាយុចាស់ជរាណាស់ទៅហើយ ។ ហើយយើងមានគោលបំណងចង់មានជាមជ្ឈមណ្ឌលវប្បធម៌សម្រាប់កូនខ្មែរជំនាន់ក្រោយ ។

អ៊ឹម លឿម : ដូច្នេះ តើលោកអាចនិយាយបានទេពីភាពខុសគ្នារវាងក្រុមអតីតយុទ្ធជនដែលដឹកនាំដោយលោក ថាច់ ម៉ារិន ហើយរូបលោកផ្ទាល់ក៏ជាអតីតនៃសមាជិកម្នាក់នៅក្នុងក្រុមនោះដែរ ។

សិរិទ្ធ ប៉ែន : ខ្ញុំចង់បកស្រាយរឿងហ្នឹងដែរកាលពីដើមឡើយខ្ញុំជាអតីតយុទ្ធជនរបស់ US-JSC ជាអក្សរកាត់ ហើយដែលមានអក្សរពេញជា United States Volunteers-Joint Services Command ។ ហើយក្រុមពីមុននោះ ជាក្រុមអតីតយុទ្ធជនចម្រុះមិនថា ខ្មែរ, លាវ,យួន,ចិនឬកូរ៉េអ្វីទេ ហើយដោយខ្ញុំយល់ឃើញថា ខ្លាចបាត់បង់ Fund របស់ខ្មែរយើងហ្នឹងទើបខ្ញុំបំបែកចេញជាសមាគមអតីតយុទ្ធជនខ្មែរពិតប្រាកដឡើងវិញ ដោយទទួលយកតែខ្មែរសុទ្ធសាធ និងក្មេងជំនាន់ក្រោយជាទំពាំងស្នង ឫស្សី ។

អ៊ឹម លឿម : ឥឡូវជាថ្មីម្តងទៀត តើលោកអាចបញ្ជាក់ឱ្យបានច្បាស់ទេថា តើក្រុមរបស់លោកហ្នឹងពិតជាបានទទួលស្គាល់ជាលក្ខណៈផ្លូវច្បាប់ពីរដ្ឋាភិបាលអាមេរិកហើយឬនៅ?

សិរិទ្ធ ប៉ែន : រឿងហ្នឹងយើងបានផ្សព្វផ្សាយរួចអស់ហើយ,យើងមានក្រដាស់ស្នាមតាមលក្ខណៈផ្លូវច្បាប់ត្រឹមត្រូវឡើងទៅលើ យើងមានក្រដាសបង់ឱ្យ IRS និងតាក់ត្រឹមត្រូវ ដូច្នេះយើងជឿជាក់ថាសហរដ្ឋអាមេរិកពិតជាទទួលស្គាល់ ។

អ៊ឹម លឿម : ចំពោះសមាជិកទាំង២៤រូបនៃក្រុមរបស់លោក ដូចដែលលោកបានជម្រាបពីមុនហ្នឹង តើពួកគាត់ទទួលបានប្រាក់បៀវត្សរ៍ណាមួយទេបាទ?

ឧត្តមសេនីយទោ សិរិទ្ធ ប៉ែន

សិរិទ្ធ ប៉ែន : ពេលនេះប្រាក់ខែពួកគាត់នៅមិនទាន់មានទេ ប៉ុន្តែតាមអ្វីដែលខ្ញុំបានដឹង បៀវត្សរ៍របស់អតីតយុទ្ធជនក្នុងសហរដ្ឋអាមេរិកចំពោះអ្នកមានសញ្ជាតិជាអាកាំង គឺគេមានបៀវត្សរ៍ត្រឹមត្រូវ មានប័ណ្ណសុខភាពត្រឹមត្រូវ ដូច្នេះហើយយើងក៏ចង់ទាមទារដល់ក្រុមខ្មែររបស់យើងឱ្យបានដូចគេដែរ ។

អ៊ឹម លឿម : គោលបំណងសំខាន់បំផុតក្នុងការបង្កើតសមាគមអតីតយុទ្ធជនខ្មែរនេះឡើង គឺផ្តោតទៅលើកត្តាសំខាន់អ្វីខ្លះ?

សិរិទ្ធ ប៉ែន : សមាគមអតីតយុទ្ធជនខ្មែរយើងនេះមានទិសដៅចំនួន៣ ដោយទី១ គឺជាអង្គការមួយសម្រាប់បំរើផ្នែកមនុស្សធម៌ ។ ទី២ សមាគមនេះគឺចង់ជួយជំរុញក្មេងជំនាន់ក្រោយ ឱ្យមានកិច្ចការងារធ្វើ ឱ្យមានការរៀនសូត្រផ្នែកអក្សរសាស្ត្រ សង្គមសាស្ត្រ ប្រវត្តិសាស្ត្រ និងប្រពៃណីខ្មែរ វប្បធម៌ខ្មែរឱ្យមានភាពល្ងូតលាស់ ។ ហើយទី៣ គឺយើងចង់រៀបចំជួយដល់អតីតយុទ្ធជនមិនថា នៅក្រៅប្រទេស ឬក្នុងប្រទេសដែលធ្លាប់ឆ្លងកាត់ក្នុងសមរភូមិដែលប្រឆាំងនិងពួកកុម្មុយនិស្តហ្នឹង គឺយើងចង់លើកស្ទួយពួកគាត់ ។

អ៊ឹម លឿម : តើក្រុមអតីតយុទ្ធជនពីមុនដែលមានលោក ថាច់ ម៉ារិន ជាអ្នកដឹកនាំ និងក្រុមអតីតយុទ្ធជនដែលដឹកនាំដោយរូបលោកផ្ទាល់ មានការសហការណ៍គ្នា ឬការនៅឃ្លាតឆ្ងាយពីគ្នាយ៉ាងណាដែលបាទ?

សិរិទ្ធ ប៉ែន : រឿងនេះឈរនៅលើគោលជំហរអ្នកដឹកនាំ ដែលគោលជំហរខ្ញុំសព្វថ្ងៃ គឺចង់ឱ្យមានការជិតស្និទ្ធគ្នាឡើងវិញ អត់ចង់ឱ្យមានការបែកបាក់គឺចង់ឱ្យមានការបង្រួបបង្រួមគ្នា ។

អ៊ឹម លឿម : ខ្ញុំបាទឃើញនូវពាក្យមួយថា "អតីតយុទ្ធជន" អ៊ីចឹងទេ មានន័យថា រាល់សមាជិកទាំងអស់ គឺសុទ្ធសឹងជាអ្នកធ្លាប់ឆ្លងកាត់ជីវិតជាអ្នកកាន់កាំភ្លើងមែនទេ?

(តទៅទំព័រទី ១៥)

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ-អង្គរ
Angkor International Travel Agency
(Since 1991)
World Wide Travel & Tour Service
Cambodia - Vietnam - Laos - Thailand
ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ សេវាអន្តោប្រវេសន៍
សេវាលិខិតឆ្លងដែន កក់សណ្ឋាគារ ឬជួលឡាន

USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com

Cambodia Office: Victory Travel (Skin Belle)
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.

SERVING SINGAPOR, EVA AIR, CHINA , ASIANA KOREAN AIRLINES,

ក្រុមហ៊ុន ទេសចរណ៍
CENTURY TRAVEL & SERVICE CENTER
904 South 8th Street. Philadelphia, PA 19147
Tel : 215-625-2889; Fax : 215-625-9395
Cell : 267-934-9888; Email : centuryphl@yahoo.com

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុងនិងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ផ្ញើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

- Serve all Airlines
- Domestic & Intl. flights
- Tour Arrangements
- Passport Extension
- Khmer Laissez- Passer
- Immigration
- Tourist Visa
- Notary Public

OFFICE Hours :
Mon - Sat 10:00 A.M - 6:00 P.M
Sun : 12:00 P.M - 5:00 P.M

We Speak Khmer, Chinese, Vietnamese
យើងនិយាយភាសាខ្មែរ_ភាសាចិន_វៀតណាម

តមកទំព័រទី ០១

ពិភពលោករំញួយដោយសារសន្និសីទ...

នៃថ្ងៃទី២៧-២៨ ខែតុលា ឆ្នាំ២០១០ ជាទិវាប្រវត្តិសាស្ត្រសំរាប់ជាតិខ្មែរទាំងមូល ត្រូវបង្ហាញនូវសាមគ្គីភាព និងបំណងរកសន្តិភាពពិតប្រាកដជាមួយនឹងប្រទេសជិតខាង គឺសៀម និងយួន។

គោលបំណង

១- បង្ហាញនូវសាមគ្គីភាពជាតិ មិនឱ្យមានការប្រមាថមាក់ងាយពីប្រទេសជិតខាង ។

២- បង្ហាញឱ្យប្រទេសជិតខាងបញ្ឈប់ជាបន្ទាន់នូវអំពើឈ្លានពានមកលើកម្ពុជា។

៣- ដើម្បីដាក់ញត្តិទាមទារឱ្យលោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិជួយដោះស្រាយបញ្ហាវិបត្តិព្រំដែនខ្មែរ ដែលកំពុងកើតមានជម្លោះជាមួយប្រទេសជិតខាង និងរើវរើពិនិត្យមើលឡើងវិញនូវការអនុវត្តន៍កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ២៣ តុលា ១៩៩១ សម្រាប់កម្ពុជា។

ញត្តិ

ជូនលោក នីកូឡា សារកូស៊ី (NICOLA SARKOZY) ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង និងជាសហប្រធាននៃសន្និសីទសន្តិភាព នៅទីក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជា

យើងខ្ញុំជាតំណាងសង្គមស៊ីវិលខ្មែរ និងជនជាតិខ្មែរ ព្រមទាំងញាតិមិត្តរស់នៅក្នុងប្រតេសបារាំង បានរួមប្រជុំគ្នាក្នុងបាតុកម្មនៅទីលានសិទ្ធិមនុស្សនៃទីក្រុងប៉ារីស នាថ្ងៃទី២៥ តុលា ២០០៩ ដើម្បីរឭកគុណនៃកិច្ចព្រមព្រៀងសន្តិភាពនៃក្រុងប៉ារីសស្តីពីកម្ពុជា ចុះថ្ងៃទី២៣ តុលា ១៩៩១។

បានសង្កេតឃើញ :

១. រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានក្តោបក្តាប់ដោយអំណាចផ្តាច់ការ... ដោយចេតនាលើសិទ្ធិមូលដ្ឋានរបស់មនុស្ស និងរបស់ពលរដ្ឋលើរដ្ឋធម្មនុញ្ញ និងលើគោលការណ៍ប្រជាធិបតេយ្យ។

២. តាំងពីឆ្នាំ១៩៩១មក ការសម្លាប់អ្នកជំទាស់នយោបាយ អ្នកសហជីព អ្នកសារព័ត៌មាន និងអ្នកច្បាប់ឯករាជ្យជាច្រើនរយនាក់...។

៣. ក្នុងបច្ចុប្បន្នកាលនេះ ការចាប់យកដីធ្លីរបស់ប្រជាជននិងការបណ្តេញប្រជាជនចេញពីទឹកដី និងលំនៅរបស់គេ...។

៤. ក្នុងបច្ចុប្បន្នកាលនេះ ការរំលោភអំណាចបានកើតមានជាអចិន្ត្រៃយ៍ដោយរដ្ឋាភិបាលនេះ បណ្តាលឱ្យកងនគរបាល កងយោធា និងបណ្តាញតុលាការ ធ្វើការសង្កត់សង្កិនយ៉ាងឃោរឃៅដោយបំពានច្បាប់ទៅលើរាល់ការទិទាន និងការតវ៉ាដ៏ត្រឹមត្រូវរបស់ពលរដ្ឋ និងអ្នកនយោបាយជំទាស់ ។

៥. ចំណែកពីខាងក្រៅស្រុកវិញ វៀតណាម ដែលបានចុះកិច្ចព្រមព្រៀងសន្តិភាពនៃទីក្រុងប៉ារីសនេះដែរ បានបន្តការធ្វើអាណានិគមឥតស្រាកស្រាន្តនៃកម្ពុជាដោយការឃប់ឃិតនៃលោក ហ៊ុន សែន និងបក្សរបស់គាត់ តាំងពីឆ្នាំ១៩៧៩មក ហើយឥឡូវនេះគេបានប្រមាណថា ពួកដែលហៅថា "អន្តោប្រវេសន៍" វៀតណាម មានចំនួនជាង៥លាននាក់ គឺជាង៣៥% នៃប្រជាជន១៤លាននាក់នៃកម្ពុជា... ។

៦. ក្នុងពេលជាមួយគ្នានេះ វៀតណាមបានបន្តការជ្រៀតជ្រែកឥតឈប់ឈរក្នុងកិច្ចការនៃរដ្ឋាភិបាលកម្ពុជា តាមរយៈនៃកិច្ចព្រមព្រៀងធ្វើ "សហប្រតិបត្តិការ" ក្នុងគ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់ទាំងអស់...។

៧. នៅមុខអំពើរំលោភគ្រប់បែបយ៉ាងនៃវៀតណាមនេះ ប្រទេសថៃ ដែលបានចុះកិច្ចព្រមព្រៀងសន្តិភាពនៃទិឍក្រុងប៉ារីស ដូចគ្នាដែរ ក៏បានចូលកាន់កាប់ទឹកដីខ្មែរជាច្រើនកន្លែង រំលោភលើសិទ្ធិរបស់ប្រជាជនខ្មែរ ក្នុងខេត្តខ្មែរខាងលិច និងខាងជើងរួមមានទាំងប្រាសាទព្រះវិហារ...។

យោងតាមសភាពការណ៍ទាំងអស់ខាងលើ យើងខ្ញុំដែលចុះហត្ថលេខាលើសេចក្តីញត្តិនេះ ដោយបានយល់ទៀតថា :

ក្រុមបាតុករនៅ San Fancisco សហរដ្ឋអាមេរិក

ក្រុមបាតុករ Ottawa កាណាដា

បន្ទាប់ពីទទួលការឈឺចាប់ឥតគណនា អំពីសង្គ្រាមរាប់សិបឆ្នាំ អំពីការសម្លាប់រង្គាល និងអំពីការកាន់កាប់ប្រទេសដោយវៀតណាមនោះ ការចុះកិច្ចព្រមព្រៀងសន្តិភាពនៃទីក្រុងប៉ារីស ស្តីពីកម្ពុជានាថ្ងៃទី ២៣ តុលា ឆ្នាំ១៩៩១ បានផ្តល់ពីដំបូងភ្លាមនូវសេចក្តីសង្ឃឹមមួយយ៉ាងធំធេងដល់ប្រជាជនខ្មែរទាំងមូល ថាគេនឹងមានសិទ្ធិសេរីភាពជាថ្មី និងរស់ក្នុងរបបប្រជាធិបតេយ្យ ហើយប្រទេសកម្ពុជានឹងមានឯករាជ្យ មានបូរណភាពទឹកដីពេញលេញវិញ។ ប៉ុន្តែក្នុងភាពជាក់ស្តែងអ្វីៗទាំងអស់បានក្លាយជាធ្ងន់ធ្ងរថែមទៀត ហើយប្រជាជន និងប្រទេសកម្ពុជានៅតែពុំបានស្គាល់សន្តិភាព និងសន្តិសុខ ដែលគេបានគ្រោងទុកនោះ និងត្រូវរស់ជានិច្ចក្នុងភាពតោកយ៉ាក និងក្នុងការភ័យរន្ធត់ចំពោះអំណាចផ្ទៃក្នុង និងចំពោះការជាន់សង្កត់នៃបរទេសជិតខាង ។

យើងខ្ញុំសូមអំពាវនាវ ដោយទទូចបំផុតដល់លោកប្រធានាធិបតីនៃសាធារណរដ្ឋ ក្នុងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកជាសហប្រធាននៃសន្និសីទសន្តិភាពនៅក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជា សូមលោកពិនិត្យនូវលទ្ធភាពនៃការបង្កើត **គណៈកម្មការអន្តរជាតិ ត្រួតពិនិត្យការអនុវត្តន៍កិច្ចព្រមព្រៀងសន្តិភាពនៃក្រុងប៉ារីស ស្តីពីកម្ពុជា** នេះដោយមានភារៈកិច្ចជំរុញឱ្យរដ្ឋាភិបាលកម្ពុជា វៀតណាម និង ថៃឡង់ គោរពយ៉ាងទៀងទាត់ចំពោះបទបញ្ញត្តិទាំងអស់នៃកិច្ចព្រមព្រៀង ដើម្បីជួយប្រទេសកម្ពុជា និងប្រជាជនឱ្យបានចាកផុតអំពីស្ថានភាពប្រកបដោយមហាគ្រោះថ្នាក់នៃការរំលាយកម្ពុជា ហើយស្ថាបនាបាននូវសន្តិភាពពេញលេញ ស្ថេរភាព និងសន្តិភាព ដើម្បីការអភិវឌ្ឍន៍ជាចាំបាច់នៃប្រទេសនេះ។

ធ្វើនៅក្រុងប៉ារីស ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១០

អ្នកតំណាងបាតុករ

ស៊ាន ប៉េងសែ	*គណៈកម្មាធិការព្រំដែនកម្ពុជា*
ថាច់ វៀន	*សហព័ន្ធខ្មែរកម្ពុជាក្រោម*
ប៉េង មុនីសាវ៉ា	*គណបក្សសមរង្ស៊ី*
លឹម ប៊ុន ស៊ីដារេត	*គណបក្សសិទ្ធិមនុស្ស*
ទី ហៃ ដានី	*សហព័ន្ធខ្មែរការពារសិទ្ធិមនុស្ស*
ឡុង តុន្តី	*សមាគមវប្បធម៌ខ្មែរ លីយ៉ុង*
លឹម គីមយ៉ា	*កិច្ចការទំនាក់ទំនងជាមួយបាតុករ*

កំណត់ : សេចក្តីញត្តិនេះ ក៏ត្រូវបានផ្ញើរជូនជាមួយគ្នាដល់

លោក ស៊ុស៊ីលោ បមបាង យុធោយោនោ (SUSILO BAMBANG YUDHOYONO) ប្រធានាធិបតីនៃសាធារណរដ្ឋ ឥណ្ឌូនេស៊ី និងជាសហប្រធាននៃសន្និសីទសន្តិភាពនៅទីក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជាដែរ ៕

សេចក្តីប្រកាសនៃគណៈកម្មាធិការព្រំដែនកម្ពុជា

នាឱកាសខួបទី១៩ នៃកិច្ចព្រមព្រៀងសន្តិភាពនាក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជា ថ្លែងដោយលោក ស៊ាន ប៉េងសែ នៅថ្ងៃទី២៤ តុលា ២០១០

បងប្អូនរួមជាតិ និងមិត្តជាទីគោរព

យើងមកជួបជុំគ្នា នាថ្ងៃនេះ នៅ"លាននៃសិទ្ធិមនុស្ស" នៃទីក្រុងប៉ារីស ដើម្បីស្រែកប្រាប់សកលលោកនូវសេចក្តីឈឺចាប់ និងកំហឹងរបស់យើងចំពោះពួកអ្នករំលោភកិច្ចព្រមព្រៀងសន្តិភាព នាទីក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជា ជាទីស្រឡាញ់របស់យើង ។ សំរែករបស់យើងនៅទីនេះ ធ្វើឡើងមិនត្រឹមតែក្នុងនាមយើងផ្ទាល់ខ្លួនទេ គឺធ្វើក្នុងនាមអ្នកស្នេហាជាតិ និងប្រជាជនខ្មែរទាំងអស់នៅក្នុងស្រុកដែរ ដែលគ្នាមិនអាចធ្វើបាតុកម្មនេះបាន ។

កិច្ចព្រមព្រៀងក្រុងប៉ារីសនេះ មានគោលដៅច្បាស់ គឺផ្តល់សន្តិភាពឱ្យកម្ពុជា និងសេរីភាពឱ្យប្រជាជនខ្មែរ។ ប៉ុន្តែវៀតណាម និងពួកខ្មែរចូលដៃជាមួយគេ ដែលបានក្បត់សេចក្តីសង្ឃឹមនៃប្រជាជនខ្លួន និងប្រយោជន៍នៃមាតុភូមិរបស់ខ្លួន បានសំរេចចិត្តបន្តនយោបាយគ្របសង្កត់ និងធ្វើសម្ពាធគ្រប់យ៉ាងមកលើស្រុកយើង និងប្រឆាំងនឹងប្រជាជនយើងជានិច្ច ។

កិច្ចព្រមព្រៀងក្រុងប៉ារីស បានដាក់កំហិតឱ្យអ្នកបានចុះហត្ថលេខាទាំងអស់គ្នា "ប្រកាន់ ថៃរក្សា និងការពារឯករាជ្យ អធិបតេយ្យ បូរណភាពដែនដី ភាពមិនអាចរំលោភបានលើដេនដីកម្ពុជា អព្យាក្រឹតភាព និងឯកភាពនៃជាតិខ្មែរ ។ ប៉ុន្តែវៀតណាមនៅតែបន្តនយោបាយវាតទីរបស់វា ដោយនៅតែបន្តការកាន់កាប់ទឹកដី សមុទ្រ និងកោះខ្មែរ ព្រមទាំងបញ្ជូនបញ្ចូលពួកយួនអាណានិគមបន្ថែមទៀត ហើយឱ្យខ្មែរទទួល "សហប្រតិបត្តិការ" របស់វា ទាំងក្នុងនិស្ស័យប៉ូលីស សន្តិសុខ យោធា ការពារជាតិ រដ្ឋបាល ច្បាប់-តុលាការទាំងអស់ជាមួយ ហ៊ុន សែន និង "បក្សប្រជាជនកម្ពុជា"របស់គាត់ ៕

DRANOFF ASSOCIATES
Attorneys at Law

"ដ្រាណុហ្វ អាសូស៊ីយេត (DRANOFF ASSOCIATE) គឺជាមណ្ឌលការពារតាមផ្លូវច្បាប់ ដែលធ្វើការប្រកបដោយភក្តីភាព ដើម្បីតំណាងឱ្យអ្នករងគ្រោះ ដែលមានរបួសរូបរាងកាយ ។

ស្ទីវិន ដ្រាណុហ្វ (STEVEN DRANOFF) គឺជាមេធាវីនៅសាលាក្តីមានបទពិសោធន៍យ៉ាងខ្ពស់ខាងសេវាច្បាប់ ៣៥ឆ្នាំ ។

យើងធ្វើការដោយយកកំរៃពីការងារដែលប្រគល់ឱ្យលោកអ្នកមិនចាំបាច់ចេញថ្លៃចំណាយអ្វីមុននឹងលោកអ្នកទទួលប្រាក់សងពីមុខរបួសលោកអ្នកនោះទេ ។

ជំនួយខាងផ្លូវច្បាប់អាចផ្តល់ជូនជាភាសា ស្បាញ៉ុល ខ្មែរ វៀតណាម កូរ៉េ និង ចិន ។

- របួសលើរាងកាយ : គ្រោះថ្នាក់រថយន្ត, ឡានឈ្នួល "សិបតា", ឡានត្រីក, តាក់ស៊ី, ជិះកង់, ថ្មើរជើង, រអិលដួលលើទឹកកក, លើចិញ្ចើមថ្នល់ ឬក្នុងអាគារលក់ទំនិញ, គ្រោះថ្នាក់ដោយបានទិញរបស់ខូចមកប្រើ ឬក៏ឆ្កែខាំ... ។
- ការប្រហែសក្នុងវិជ្ជាជីវៈ និងសិទ្ធិរបស់អតិថិជន : ព្យាបាលតាមវិជ្ជាពេទ្យពុំបានត្រឹមត្រូវ, មរណភាពឥតសមហេតុផល, វាយមាយក្នុងការថែទាំមនុស្ស... ។

DRANOFF ASSOCIATES
121 South Broad Street, Suit 1210, Philadelphia, PA 19107
215-732-3333 (phone) 215-732-8059 (fax)
sdranoff@dranofflaw.com

រំឭកថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣

ដោយ : ម៉ម យីន

ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ គឺជាថ្ងៃនៃប្រវត្តិសាស្ត្រខ្មែរមួយ ដែលជនជាតិខ្មែរ បានចូលរួមបំពេញបូជនីយកិច្ចនៅក្នុងការតវ៉ាទាមទារឯករាជ្យពេញបរិបូរសម្រាប់មាតុភូមិ និងជនជាតិខ្មែរ ឱ្យបានចេញផុតពីអំណាចអណានិគមនិយមបារាំងសែស ។

ឯករាជ្យពេញបរិបូរ មិនមែនបានមកដោយសារតែមេដឹកនាំតែម្នាក់ឯងនោះទេ ឈាមស្រស់ និងជីវិតជនជាតិខ្មែរស្នេហាជាតិ មាតុភូមិរាប់ម៉ឺន-សែននាក់ បានពលីចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៤៥មកបានប្រឆាំងនឹងការត្រួតត្រានៃអាណានិគមនិយមបារាំង ។

កម្លាំងកងទ័ពប្រដាប់អាវុធខ្មែរឥស្សរៈ បានរត់ចូលព្រៃភ្នំក្រថ្ម ដើម្បីវាយអុកឡុកកងទ័ព ក្រោមបញ្ជាការនាយទាហានបារាំង យ៉ាងអង់អាចក្លាហានបំផុត រួមគ្នាជាមួយការក្រោកឈរនៃប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ។

ដោយសារតែទឹកចិត្ត គោលជំហរ សតិស្មារតីមនសិការ ឆន្ទៈ ប្តេជាតស៊ូ លះបង់ប្តូរផ្តាច់នេះហើយ ទើបបណ្តាលឱ្យព្រះរាជាខ្មែរ ត្រូវតែស្តេចចេញចរចាតវ៉ាទាមទារឯករាជ្យពេញបរិបូរក្នុងនាមព្រះអង្គជាស្តេចម្ចាស់ផែនដី ដោយមានវិរជនសំខាន់ៗមួយចំនួនធ្វើជាក្រុមប្រឹក្សាអមព្រះអង្គផង ។

អាណានិគមនិយមបារាំង ក្រោយពីបានដឹង និងឃើញសន្ទះទឹកចិត្តនៃជនជាតិខ្មែរដូច្នេះហើយ ទើបសម្រេចចិត្តថា ត្រូវតែយល់ព្រមប្រគល់ឯករាជ្យពេញបរិបូរដល់ប្រទេស និងជនជាតិខ្មែរ នាថ្ងៃទី៩ វិច្ឆិកា ឆ្នាំ១៩៥៣ ។

ជនជាតិខ្មែរ បានចាត់ទុកថ្ងៃនេះ ជាថ្ងៃរំឭកបុណ្យខួបឯករាជ្យជារៀងរាល់ឆ្នាំ ហើយចារឹកទុកជាថ្ងៃប្រវត្តិសាស្ត្រនៃជោគជ័យដ៏ឧត្តមខ្ពស់ខ្ពង់បំផុត ។

ពីមួយឆ្នាំទៅមួយឆ្នាំ ឱ្យតែដល់ថ្ងៃទី៩ ខែវិច្ឆិកា ជនជាតិខ្មែរទូទាំងប្រទេស រួមជាមួយមេដឹកនាំ និងរដ្ឋាភិបាល តែងតែប្រារព្ធធ្វើបុណ្យទិវារំឭកថ្ងៃខួបកំណើតឯករាជ្យពេញបរិបូររបស់មាតុភូមិជាតិខ្មែរ ដោយអធឹកអធម ប្រមូលផ្តុំគ្នាមកជួបជុំសម្តែងព្យុហយាត្រាតាមមហាវិថីនានា ក្រោមសម្លេងស្រែកជ័យឃោសហ៊ោកញ្ជ្រៀវ គឹកកងរពង ក្នុងក្តីសាមគ្គីមិត្តភាព និងភាតរភាព ក្នុងរយៈពេលមួយថ្ងៃដ៏មហាឡារីកក្រៃលែងនេះ ។

តើមានរយៈពេលប៉ុន្មានឆ្នាំ ដែលមាតុភូមិ និងជនជាតិខ្មែរបានឃើញពន្លឺរស្មី? រួចហើយបានរលាយអស់នូវសេចក្តីសង្ឃឹមទាំងនោះទៅវិញ?

ប្រមាណជាង១០ឆ្នាំប៉ុណ្ណោះ មកដល់ឆ្នាំ១៩៦៩-១៩៧០ មាតុភូមិ និងជនជាតិខ្មែរបានចាប់ផ្តើមមានអសន្តិសុខផ្ទុះចេញជាភ្លើងសង្គ្រាមក្នុងស្រុក ដែលជនជាតិខ្មែរមើលឃើញ ពិតជាកើតចេញមកពីកងទ័ពព្រៃយួន យៀកកុងកុម្មុយនីស្តយួនខាងជើង បានចូលមកជ្រកពួននៅក្នុងប្រទេសខ្មែរ ដើម្បីចេញទៅវាយប្រយុទ្ធរំដោះដែនដីយួនខាងត្បូង ដែលជាអតីតដែលដីថ្មីខ្មែរកម្ពុជាក្រោម ។

សង្គ្រាមនេះ កើតចេញមកពីកងទ័ពយួនព្រៃយៀកកុង បើកវាយប្រហារមកលើកងទ័ពជាតិខ្មែរ ដែលជាម្ចាស់ស្រុក ដែលពុំឱ្យយៀកកុងច្រកពួននៅក្នុងស្រុកខ្មែរតទៅទៀត ក្រោយពីរដ្ឋសភា បានបោះឆ្នោតអនុម័តដកតំណែងពីសម្តេចប្រមុខរដ្ឋកម្ពុជា កាលពីថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ។

ព្រឹត្តិការណ៍កើតជាភ្លើងសង្គ្រាមឆាបឆេះឡើង ក្រោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០នោះ ហើយដែលចាប់ផ្តើមឱ្យជនជាតិខ្មែរ យល់ដឹងថា ឯករាជ្យពេញបរិបូរថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ត្រូវបានប្រទេសជិតខាង គឺយួនកំហែងគម្រាមហើយ រួចហើយនឹងអាចបាត់បង់ជាពិតប្រាកដ បើសិនជា កងទ័ពជាតិខ្មែរ ទ្រទ្រង់ការពារ ទប់ទល់នឹងការវាយប្រហាររបស់យួនព្រៃយៀកកុងនោះពុំបានទេ ។

គួរឱ្យអនិច្ចា និងសង្វេគដល់ជីវិតយុទ្ធជននៃកងទ័ពជាតិ និងជនជាតិខ្មែរខ្លាំងណាស់ នៅក្នុងភ្លើងសង្គ្រាមនេះ បានធ្វើឱ្យបាត់បង់ជីវិតអស់ប្រមាណជិតមួយលាននាក់ ។ បន្ទាប់មក ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហម គាំទ្រដោយយួនក្រហម ចិនក្រហម និងកូរ៉េក្រហម បានយកជោគជ័យជំនិះបានដោយចុងកាណុងដ៏ត្រចះត្រចង់ក្រោមទង់ជ័យដ៏ក្រហមឆ្អិនឆ្អៅនៃកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា ។

ចាប់តាំងពីឆ្នាំ១៩៧០នោះហើយ ដែលទិវាថ្ងៃបុណ្យខួបឯករាជ្យខ្មែរត្រូវបានបាត់បង់ទៅ ហើយបានក្លាយទៅជាប្រទេស និងជនជាតិរស់នៅក្រោមអំណាចផ្តាច់ការការសម្លាប់ជនជាតិខ្មែរអស់ជាប្រមាណជាងបី (៣)លាននាក់ នៅក្នុងរបបកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ ។

លុះមកដល់ឆ្នាំ១៩៧៩ មានព្រឹត្តិការណ៍មួយទៀត បង្កើតឡើងដោយកងទ័ពយួនវៀតណាមសង្គមនិយមប្រមាណពីរ(២)សែននាក់ និងអ្នកជំនាញការ ទីប្រឹក្សាពីរពាន់នាក់ បានលើកទ័ពចូលវាយលុកលុយដេញកំចាត់ខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យ ដោយយកលេសថា ជួយសង្គ្រោះជីវិតខ្មែរឱ្យរួចពីខ្មែរក្រហម ។ រួចហើយកងទ័ពយួនបានតែងតាំងក្រុមមេដឹកនាំថ្មីមួយ ដែលនៅក្រោមបញ្ជាកងទ័ព និងអ្នកជំនាញការ ទីប្រឹក្សាយួនយៀកណាមហ្វេតមកដល់សព្វថ្ងៃនេះ ។

ក្រុមមេដឹកនាំថ្មីនេះ បានកំណត់យកថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃជោគជ័យដែលគេសន្មតប្រទេសខ្មែរថា ជាប្រទេសគ្មានការដឹកនាំគ្រប់គ្រងពេញលក្ខណៈទេ **(តទៅទំព័រទី ០៩)**

KhmerPost USA, LLC
East Coast Publication

Pin Samkhon,
Publisher & Editor-in-Chief
Email: pinsamkhon@gmail.com
Staff Writers: **Loeum Im,**
Eda Uong & Audria Chea

Contributed Writers:
Mam Yin, Kim Phien,
Lanica Angpak, & Dannely Sam
KhmerPostLowell@gmail.com

Soben Pin
Marketing Director
KhmerPostUSA@gmail.com
267-253-3947

Sophal Meas
Branch Manager, New England
978-758-8547

Design Staffs:
Leang Heng & Doch Vuthy
Distributor: ***Chharly Young***

The Khmer Post, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local, community, and national news; and give an insight into Cambodia & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Philadelphia, Pennsylvania.

Semimonthly edition subscription is available within the U.S. & Canada at $60.00 and 70 Euros in Europe per year. Money order or check is accepted and made payable to:
U.A.M.G.
P.O. Box 24357
Philadelphia, Pa 19120

The Khmer Post has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

ART OF WELLNESS CENTER

Art of Wellness
"Integrating Holistic Healthcare for the Mind, Body, and Spirit."
(215)305-2238
www.artofwellnesscenter.com

មន្ទីរសុខភាព "Art Wellness" ទទួលព្យាបាលបញ្ហាផ្លូវចិត្ត និងធ្វើទៅតាមទម្លាប់ និងជំនឿរបស់លោកអ្នក ដោយប្រើរបៀបបច្ចេកទេសអាស៊ី និងបច្ចេកវិទ្យាបស្ចិមប្រទេស ។
ចំពោះលោកអ្នកមានការលំបាកណាមួយដូចចំណុចខាងក្រោម :

- ធ្លាក់ទឹកចិត្ត DEPRESSION
- ការថប់អារម្មណ៍ ANXIETY
- ភាពតានតឹង STRESS
- មានកំហឹងច្រើន ANGER MANAGEMENT
- ឈឺខ្លួនប្រាណគ្រប់កន្លែង PAIN MANAGEMENT
- មានវិបត្តិក្នុងគ្រួសារ FAMILY ISSUES
- ការញៀន និងអ្វីមួយ ADDICTION ISSUES
- សុខភាពស្ត្រី WOMEN'S HEALTH

- Allergy Testing & Elimination
- Weight Managerment for Adult & Children
- Diabetes
- High Blood Pressure
- High Cholesterol Level Issue
- រកប្រតិកម្មនឹងធាតុអ្វីមួយ ហើយបំបាត់វាចេញ
- គ្រប់គ្រងទម្ងន់សម្រាប់ចាស់និងក្មេង
- ទឹកនោមផ្អែម
- លើសសម្ពាធឈាម
- លើសកំរិត កូលេសស្តេរ៉ូល
- Insomnia (Difficulty Sleeping)
- Facial Acupuncture (reduce wrinkles)
- Nutrition Consultation (Free)
- Genetic Testing
- Feeling Tired & Weak
- We Accept AETNA & United Healthcare
- ដេកមិនលក់
- ប្រើម្ជុលព្យាបាលលើផ្ទៃមុខ (បន្ថយភាពជ្រីវជ្រួញ)
- ពិគ្រោះពីម្ហូបអាហារ (មិនយកកំរៃ)
- ធ្វើតេស្តអំពូជ
- អស់កម្លាំង មិនស្រួលខ្លួន
- យើងទទួលយក AETNA និង UNITED HEALTHCARE

ទទួលព្យាបាលគ្រប់វ័យ

ទទួលព្យាបាលគ្រប់បែប TREATMENT TYPE
- ប្រើម្ជុលឥតថ្នាំ
- ចាប់សរសៃ
- ចិត្តវិទ្យា
- យោគ/ភាវនា
- Acupuncture
- Acupressure
- Psychotherapy
- Yoga/ Meditation

វេជ្ជបណ្ឌិតនឹងអ្នកជំនាញការមានបទពិសោធន៍ច្រើនឆ្នាំនៅប្រទេសចិន និងនៅសហរដ្ឋអាមេរិក ។
សូមអញ្ជើញទូរស័ព្ទ ឬមកមន្ទីរពេទ្យសុខភាពយើងខ្ញុំ ដើម្បីពិគ្រោះវិធីព្យាបាល

ART OF WELLNESS CENTER
647 BAINBRIDGE STREET,
PHILADELPHIA, PA 19147
215-305-2238
ភាសាខ្មែរទាក់ទង ប៊ុន វ៉ាត់ : 267-242-8526

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី២៩៤ ខែតុលា ឆ្នាំ២០១០

Jailed Journalist to Be Freed, Has Sentence Slashed

By Eang Mengleng
THE CAMBODIA DAILY

The Court of Appeal yesterday upheld jailed journalist Ros Sokhet's conviction for disinformation but reduced his sentence from two years in prison to one, court officials said.

"The Court of Appeal decided to change the Municipal Court conviction from two years in prison to one year," Judge Pol Sam Oeun said.

Mr Sokhet has been in jail for one year since his arrest in October last year for sending disparaging text messages to television personality Soy Sopheap. Mr Sokhet's lawyer Sam Sokong said he expected Mr Sokhet to be released as soon as a judge's order reached Prey Sar prison, where he is incarcerated.

"My client will be released soon because...Ros Sokhet was jailed for one year in total now," Mr Sokong said, adding that the process usually took one or two days.

It was unclear yesterday whether a letter penned by Information Minister Khieu Kanharith and sent to the Justice Ministry on Oct 14 requesting the journalist's release had reached the court.

Judge Sam Oeun did not mention the letter as he read out the decision.

"I did not see the letter from the information minister yet," Mr Sokong said. Mr Kanharith did not respond to requests for comment.

Ros Sokhet's sister, Ros Rada, said she was happy that her brother had been freed but maintained that he should never have been jailed.

"He was not guilty.... I will go to meet him at the prison to welcome him with a family reunion," Ms Rada said.

Pen Samitthy, president of the Club of Cambodian Journalists, said he was glad Mr Sokhet would soon be free but that the journalist had been incorrectly charged in the first place.

"I encourage Ros Sokhet after leaving jail to do any action to make clear that he is innocent."

(Additional reporting by LucJordan)

អ្នកកាសែតនឹងត្រូវដោះលែង ទោសត្រូវបានសម្រាល

ដោយ : អ៊ាង ម៉េងឡេង
The Cambodia Daily

ក្រុមមន្ត្រីតុលាការបាននិយាយថា កាលពីម្សិលមិញសាលាឧទ្ធរណ៍បានតម្កល់ការដាក់ទោសអ្នកកាសែតឈ្មោះ រស់ សុឃិត ពីបទផ្សព្វផ្សាយព័តិមានមិនពិត ប៉ុន្តែបានសម្រាលទោសរបស់គាត់ពី២ឆ្នាំក្នុងពន្ធនាគារមកត្រឹមមួយឆ្នាំវិញ ។

លោកចៅក្រម ប៉ុល សំអឿន បានមានប្រសាសន៍ថា "សាលាឧទ្ធរណ៍បានសម្រេចកែប្រែការដាក់ទោសដោយតុលាការក្រុងពីរយៈពេល២ឆ្នាំក្នុងពន្ធនាគារមកត្រឹមរយៈពេល១ឆ្នាំវិញ ។

ពន្ធនាគាររយៈពេល១ឆ្នាំហើយ ចាប់តាំងពីការចាប់ខ្លួនលោកខែតុលាឆ្នាំមុនមក ពីបទបញ្ជូនសារបន្ទុះបង្អាប់លោក សយ សុភាព ដែលជាអ្នកធ្វើអត្ថាធិប្បាយដ៏ល្បីប្រចាំស្ថានីយ៍ទូរទស្សន៍មួយ ។ លោក សំ សុខគង់ មេធាវីរបស់លោក សុឃិត បានថ្លែងថា លោករំពឹងថា លោក សុឃិត នឹងត្រូវបានដោះលែងនៅពេលដែលលិខិតបង្គាប់មួយរបស់ចៅក្រមទៅដល់ពន្ធនាគារព្រៃសជាទីដែលលោកកំពុងតែជាប់ ។

លោក សុខគង់ បានថ្លែងថា "កូនក្តីរបស់ខ្ញុំនឹងត្រូវដោះលែងឆាប់ៗនេះ ពីព្រោះលោក រស់ សុឃិត បានជាប់ពន្ធនាគាររយៈពេលសរុប១ឆ្នាំហើយពេលនេះ" ដោយលោកបន្ថែមថា នីតិវិធីជាធម្មតាប្រើពេលពី១ថ្ងៃទៅ២ថ្ងៃ ។

គេនៅមិនទាន់ច្បាស់ទេ កាលពីម្សិលមិញនេះថាតើលិខិតមួយច្បាប់ដែលសរសេរដោយលោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័តិមានផ្ញើទៅក្រសួងយុត្តិធម៌កាលពីថ្ងៃទី១៥ ខែតុលា ដោយស្នើឱ្យដោះលែងអ្នកកាសែតរូបនេះ បានទៅដល់តុលាការហើយឬយ៉ាងណានោះ ។ លោកចៅក្រម សំអឿន មិនបានលើកឡើងអំពីលិខិតនេះទេ ខណៈដែលលោកអានសេចក្តីសម្រេច ។

លោក សុខគង់ បានថ្លែងថា "ខ្ញុំមិនទាន់ឃើញលិខិតពីលោក ខៀវ កាញារីទ្ធ នៅឡើយទេ" ។ លោក ខៀវ កាញារីទ្ធ មិនបានឆ្លើយតបនឹងសំណើរសុំធ្វើអត្ថាធិប្បាយឡើយ ។

បងប្អូនស្រីរបស់លោក រស់ សុឃិត ឈ្មោះ រស់ រ៉ាដា បានឱ្យដឹងថា អ្នកស្រីរីករាយដែលបងប្អូនប្រុសរបស់អ្នកស្រីត្រូវបានដោះលែង ប៉ុន្តែអ្នកស្រីបានអះអាងថាលោក រស់ សុឃិត មិនគួរត្រូវជាប់ពន្ធនាគារទេ ។

អ្នកស្រី រ៉ាដា បានថ្លែងថា "លោកគ្មានកំហុសទេ... ។ ខ្ញុំនឹងទៅជួបគាត់នៅពន្ធនាគារដើម្បីទទួលគាត់មកជួបជុំគ្រួសារវិញ " ។

លោក ប៉ែន សមិទ្ធិ ប្រធានក្លឹបអ្នកកាសែតកម្ពុជា បានថ្លែងថា លោករីករាយដែលលោក សុឃិត នឹងត្រូវដោះលែងឆាប់ៗនៅ ប៉ុន្តែថា អ្នកកាសែតរូបនេះត្រូវបានចោទប្រកាន់ខុសតាំងពីដំបូងម្ល៉េះ ។

លោកបានថ្លែងថា "ប្រសិនបើខ្ញុំនិយាយអ្វីខុសចំពោះមុគ្គលណាម្នាក់ នេះមិនមែនជាការផ្សព្វផ្សាយព័តិមានមិនពិតនោះទេ វាជាការបង្ខូចកេរ្តិ៍ឈ្មោះ ។ ប៉ុន្តែវាលំបាកណាស់ ពីព្រោះប្រសិនបើអ្នកទទួលយកការដោះលែងហើយ មានន័យថា អ្នកទទួលស្គាល់ថា អ្នកមានកំហុសមែន ។ ខ្ញុំលើកទឹកចិត្តលោក រស់ សុឃិត បន្ទាប់ពីចេញពីពន្ធនាគារ ដើម្បីធ្វើឱ្យប្រាកដថា លោកគ្មានកំហុសទេ" ៕

(រាយការណ៍បន្ថែមដោយ Lucy Jordan)

Crackdown on Protesters 'Excessive,' UN Says

By Chhorn Chansy
and Ian Williamson
THE CAMBODIA DAILY

Police in Phnom Penh were involved in a violent clash with Boeng Kak lake residents that injured one villager yesterday as the protesters tried to present a petition to visiting UN Secretary-General Ban Ki-moon, rights groups said.

At about 10:15 am, a joint force of municipal intervention police and Chamkar Mon district police "launched a violent assault" to break up a gathering of about 50 villagers in front of the Khmer-Soviet Friendship Hospital, according to a statement released yesterday by the human rights group Licadho.

Mr Ban was visiting the hospital at the time of the incident.

Soung Sophorn, 23, a law school graduate who led the demonstration, claimed police struck him repeatedly as they broke up the peaceful protest.

"I was beaten six or seven times on the head with a walkie-talkie, and the blood wet my shirt," he said.

Mr Sophorn, who claims he was briefly detained after the incident, said authorities took him to Daun Penh district health center to treat his head wounds. He said he was only released after signing a document promising not to lead any more protests.

"I did the promise with them, but I want to confirm that I will still defend my people until I die," he said.

Boeng Kak residents have been engaged in an ongoing struggle to preserve their homes after the government approved a development in the area expected to displace about 4,000 families. According to the Licadho statement, Mr Sophorn was convicted of defamation in June last year for protesting the eviction.

Deputy UN High Commissioner for Human Rights Kang Kyung-wha, based in Geneva, but part of the delegation visiting with Mr Ban, criticized the police response yesterday.

"I am aware of the incident. I have expressed concern in person to the Ministry of Interior about this incident and the excessive use of force used against the petitioners and Mr Soung Sophorn specifically," she wrote in an e-mail yesterday.

"The office here has been in communication with the police this morning, who released Mr Soung this afternoon as promised. I have also received the petition of the Boeng Kak lake community on behalf of the secretary-general," she added.

Kong Chantha, a resident in the district's village 24, said police used electric batons to break up the protest.

"Their actions were very brutal. Even though [some protesters] were women, they did not forgive," she said, adding that she suffered bruising after being punched in the head by one police officer.

Outside the hospital yesterday, Deputy Daun Penh district governor Sok Penhvuth said Mr Sophorn had not been beaten or arrested.

"He probably got injured when police sent him into the car, and he hit the door to get injured. We just brought him for treatment, and right now he can go return home," he said.

Chamkar Mon district Police Chief Ouch Sokhon claimed police did not use violence against the protesters.

"Don't believe them. No one fought them. [Police] just pushed them away because it affected public order," he said. "No country would allow [protesters] to go in to an event when it has started."

Rights groups were also quick to condemn police actions.

"While the Cambodian government entertains an empty dialogue on human rights with the UN secretary-general, its armed forces are cracking down on freedom of expression. This incident has further exposed the cracking facade of democracy in Cambodia," Pung Chhiv Kek, Licadho's president, said in the group's statement.

Sia Phearum, secretary-general of the Housing Rights Task Force, said Mr Ban's visit should have been an opportunity for the lake residents to air their grievances.

"The UN secretary-general coming here is a chance to ask...leaders to help [villagers] because they are living under the threat of forced eviction," he said.

អង្គការសហប្រជាជាតិនិយាយថា ការប្រើកម្លាំងដើម្បីបង្ក្រាបលើអ្នកតវ៉ាជ្រុលហួស

ដោយ ឆន ចាន់ស៊ី និង Ian Williamson
THE CAMBODIA DAILY

ក្រុមអង្គការសិទ្ធិមនុស្សបានអះអាងថា ប៉ូលិសក្រុងភ្នំពេញ បានជាប់ពាក់ព័ន្ធនៅក្នុងការប៉ះទង្គិចគ្នាដ៏ហិង្សាមួយជាមួយអ្នកភូមិនៅតំបន់បឹងកក់ ដោយបានធ្វើឱ្យអ្នកភូមិម្នាក់រងរបួសកាលពីម្សិលមិញ ខណៈពេលក្រុមអ្នកតវ៉ាព្យាយាមប្រគល់ញត្តិមួយជូនលោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលកំពុងធ្វើទស្សនកិច្ច ។

[illegible]/The Cambodia Daily
A joint force of municipal intervention police and Chamkar Mon district police restrain Boeng Kak villager Soung Sophorn, 23, as he and other residents try to present a petition to UN Secretary-General Ban Ki-moon, outside the Khmer-Soviet Friendship Hospital in Phnom Penh, yesterday.

យោងតាមសេចក្តីថ្លែងការមួយ ដែលចេញផ្សាយកាលពីម្សិលមិញ ដោយអង្គការសិទ្ធិមនុស្សលីកាដូបានឱ្យដឹងថា នៅម៉ោងប្រមាណ១០:១៥នាទីព្រឹក កងកម្លាំងចម្រុះនៃប៉ូលិសអន្តរាគមន៍ក្រុងនិងប៉ូលិសខណ្ឌចំការមន "បានធ្វើការបង្ក្រាប់ដ៏ហិង្សា" ដើម្បីបំបែកការប្រមូលផ្តុំរបស់ក្រុមអ្នកភូមិដែលមានគ្នាប្រមាណ៥០នាក់ នៅមុខមន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត ។

ឧប្បត្តិហេតុនេះបានកើតមានពេលដែលលោក បាន គីមូន កំពុងធ្វើទស្សនកិច្ចមន្ទីរពេទ្យនេះ ។ លោក សួង សុភ័ណ អាយុ២៣ឆ្នាំ ជានិស្សិតបញ្ចប់ការសិក្សាផ្នែកច្បាប់ដែលបានដឹកនាំបាតុកម្មនេះ បានអះអាងថា ប៉ូលិសបានវាយគាត់ផ្ទួនៗ ខណៈដែលពួកគេបំបែកការតវ៉ាដោយសន្តិវិធីនេះ ។

លោកបាននិយាយថា "ខ្ញុំត្រូវបានវាយនឹងវិទ្យុទាក់ទង៦ឬ៧ដងត្រង់ក្បាល ហើយឈាមបានហូរជោកអាវរបស់ខ្ញុំ" ។

លោក សួង សុភ័ណ ដែលអះអាងថា ខ្លួនត្រូវបានឃុំខ្លួនមួយរយៈខ្លីបន្ទាប់ពីឧប្បត្តិហេតុនេះនោះ បាននិយាយថា ក្រុមអាជ្ញាធរបានបញ្ជូនលោកទៅមណ្ឌលសុខភាពនៅខណ្ឌដូនពេញ ដើម្បីព្យាបាលរបួសក្បាលរបស់លោក ។

លោកបាននិយាយថា ខ្លួនត្រូវបានដោះលែងតែនៅក្រោយពេលចុះហត្ថលេខាលើក្រដាសស្នាមមួយ ដោយសន្យាឈប់ដឹកនាំការតវ៉ាបន្តទៅទៀតតែប៉ុណ្ណោះ ។ លោកបានបន្ថែមថា "ខ្ញុំបានសន្យាជាមួយពួកគេមែន ប៉ុន្តែខ្ញុំចង់បញ្ជាក់ថា ខ្ញុំនឹងនៅតែការពារប្រជាពលរដ្ឋរបស់ខ្ញុំរហូតដល់ខ្ញុំស្លាប់" ។

អ្នកស្រុកនៅតំបន់បឹងកក់ បានចូលរួមនៅក្នុងការប្រឹងប្រែងតស៊ូជាបន្តបន្ទាប់ ដើម្បីរក្សាផ្ទះរបស់ពួកគាត់ក្រោយពីរដ្ឋាភិបាល បានយល់ព្រមឱ្យមានការអភិវឌ្ឍន៍មួយនៅក្នុងតំបន់នេះ ដែលគេរំពឹងថានឹងត្រូវផ្លាស់ទីលំនៅប្រជាជនប្រហែលជា៤០០០គ្រួសារ ។

យោងតាមសេចក្តីថ្លែងការណ៍របស់អង្គការលីកាដូ បានឱ្យដឹងថា លោក សួង សុភ័ណ ត្រូវបានកាត់ទោសពីបទបរិហារកេរ្តិ៍កាលពីខែមិថុនា ឆ្នាំមុនដោយសារការតវ៉ាចំពោះការបណ្តេញចេញនេះ ។

លោកស្រី Kang Kyung-wha ឧត្តមស្នងការរងសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សដែលមានមូលដ្ឋាននៅទីក្រុងហ្សឺណែវ ប៉ុន្តែដែលក៏ជាសមាជិកម្នាក់នៃគណៈប្រតិភូដែលកំពុងធ្វើទស្សនកិច្ចជាមួយលោក បាន គីមូន បានរិះគន់ការឆ្លើយតបរបស់ប៉ូលិសកាលពីម្សិលមិញ ។

លោកស្រីបានសរសេរនៅក្នុងអ៊ីម៉ែលមួយកាលពីម្សិលមិញថា "ខ្ញុំបានដឹងអំពីឧប្បត្តិហេតុនេះ ។ ខ្ញុំបានសំដែងការព្រួយបារម្ភដោយផ្ទាល់ទៅការក្រសួងមហាផ្ទៃអំពីឧប្បត្តិហេតុនេះ និងការប្រើកម្លាំងជ្រុលហួសប្រឆាំងនឹងក្រុមអ្នកជូនញត្តិតវ៉ា ជាពិសេស គឺលោក សួង សុភ័ណ" តែម្តង ។ លោកស្រីបានបន្ថែមថា "ការិយាល័យនៅទីនេះបានទាក់ទងជាមួយប៉ូលិសកាលពីម្សិលមិញ ដែលបានដោះលែងលោក សួង សុភ័ណ កាលពីរសៀលដូចដែលបានសន្យា ។ ខ្ញុំក៏បានទទួលញត្តិរបស់សហគមន៍បឹងកក់ជូនសមុខឱ្យលោកអគ្គលេខាធិការផងដែរ" ។

លោកស្រី គង់ ចាន់ថា ជាអ្នកស្រុកនៅភូមិ២៤ក្នុងខណ្ឌនេះ បាននិយាយថា ប៉ូលិសបានប្រើដំបងឆក់ដើម្បីបំបែកការតវ៉ានេះ ។

អ្នកស្រីបាននិយាយថា "សកម្មភាពរបស់ពួកគេសាហាវណាស់ ។ សូម្បី (អ្នកតវ៉ាខ្លះ) ជាស្ត្រីក៏ពួកគេមិនលើកលែងឱ្យដែរ" ដោយបានបន្ថែមថា អ្នកស្រីមានស្នាមជាំក្រោយពីត្រូវបានមន្ត្រីប៉ូលិសម្នាក់ដាល់ចំក្បាល ។

ដោយត្រូវបានសម្ភាសន៍នៅក្រៅមន្ទីរពេទ្យកាលពីម្សិលមិញ លោក សុខ ពេញវុធ អភិបាលរងខណ្ឌដូនពេញ បានមានប្រសាសន៍ថា លោក សួង សុភ័ណ មិនត្រូវបានវាយឬចាប់ខ្លួនទេ ។

លោកបានមានប្រសាសន៍ថា គាត់ប្រហែលជារងរបួសនៅពេលដែលប៉ូលិសចាប់បញ្ជូនគាត់ចូលទៅក្នុងរថយន្ត ហើយគាត់បុកនឹងទ្វារធ្វើឱ្យរងរបួស ។ យើងទើបតែបាននាំគាត់មកព្យាបាល ហើយឥឡូវនេះគាត់អាចត្រឡប់ទៅផ្ទះវិញបានហើយ" ។

លោក អ៊ូច សុខុន អធិការប៉ូលិសខណ្ឌចំការមន បានអះអាងថា ប៉ូលិសមិនបានប្រើអំពើហិង្សាលើក្រុមអ្នកតវ៉ាទេ ។

លោកបានមានប្រសាសន៍ថា "កុំជឿពួកគេ ។ គ្មាននរណាវាយពួកគេទេ ។ (ប៉ូលិស) គ្រាន់តែរុញពួកគាត់ចេញឱ្យឆ្ងាយប៉ុណ្ណោះ ពីព្រោះវាប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ។ គ្មានប្រទេសណាអនុញ្ញាតឱ្យ (ក្រុមអ្នកតវ៉ា) ចូលទៅក្នុងកម្មវិធីនៅពេលដែលវាចាប់ផ្តើមនោះទេ" ។

ក្រុមអង្គការសិទ្ធិមនុស្សក៏បានថ្កោលទោសភ្លាមៗ ចំពោះសកម្មភាពរបស់ប៉ូលិសផងដែរ ។

លោកស្រី ពង្ស ឈីវហ្គេក ប្រធានអង្គការសិទ្ធិមនុស្សលីកាដូ បានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍របស់អង្គការនេះថា "ខណៈដែលរដ្ឋាភិបាលកម្ពុជាកំពុងធ្វើការពិភាក្សាដោយស្មោះត្រង់ស្តីពីបញ្ហាសិទ្ធិមនុស្សអគ្គលេខាធិការអង្គការសហប្រជាជាតិនោះ កម្លាំងប្រដាប់អាវុធរបស់ខ្លួនបែរជាកំពុងតែបង្ក្រាបទៅលើសេរីភាពនៃការបញ្ចេញមតិទៅវិញ ។ ឧប្បត្តិហេតុនេះបានបង្ហាញកាន់តែច្បាស់ពីមុខមាត់ក្លែងក្លាយនៃប្រជាធិបតេយ្យនៅក្នុងប្រទេស កម្ពុជា" ។

លោក សៀ ភារម្យ អគ្គលេខាធិការក្រុមការងារសិទ្ធិលំនៅដ្ឋានបានមានប្រសាសន៍ថា ដំណើរទស្សនកិច្ចរបស់លោក បាន គីមូន គួរតែជាឱកាសមួយសម្រាប់អ្នកស្រុកនៅតំបន់បងេកក់ដើម្បីសំដែងសាទុក្ខរបស់ខ្លួន ។

លោកបានមានប្រសាសន៍ថា "វត្តមានរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិនៅទីនេះ គឺជាឱកាសមួយដើម្បីស្នើឱ្យ... ក្រុមមេដឹកនាំជួយ (ក្រុមអ្នកភូមិ) ពីព្រោះពួកគាត់កំពុងរស់នៅក្រោមការគំរាមកំហែងបណ្តេញចេញដោយបង្ខំ" ។

លោកបានបន្ថែមថា "លោកអគ្គលេខាធិការត្រូវតែយកចិត្តទុកដាក់ឱ្យបានខ្លាំងឡើងចំពោះករណីនេះ" ៕

តមកទំព័រទី ០៧

រំឭកថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣...

ដោយតែមេដឹកនាំកាល ពីក្រោយថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣នេះហើយ ពុំមានសមត្ថភាពគ្រប់គ្រាន់ ដូច្នេះគឺថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នេះហើយជាថ្ងៃ ធ្វើឱ្យប្រទេសកម្ពុជាមានសន្តិភាព រីកចំរើនល្អូតលាស់គ្រប់វិស័យ និងមានមេដឹកនាំមានប្រាជ្ញាឈ្លៀវឆ្លាត មានឧត្តមគតិ ហើយនិងគតិយុត្តិធម៌ល្អជាងមេដឹកនាំខ្មែរពីសម័យមុនៗទាំងអស់។

ទោះបីជាមានជនជាតិខ្មែរជាច្រើន មានទស្សនៈយល់ឃើញថា ការថ្លែងប្រកាសរបស់មេដឹកនាំខ្មែរនេះ គឺជាគំនិតផ្ទាល់ខ្លួនតែម្នាក់ឯងប៉ុណ្ណោះ តាមការពិតដែលជាតិខ្មែរបានឃើញនោះ វាពុំមានអ្វីបង្ហាញពីឯករាជ្យភាពពិតប្រាកដនៅក្នុងមាតុភូមិខ្មែរទាល់តែសោះ កាលបើប្រៀបធៀបទៅនឹងប្រទេសនានា ដូចជាប្រទេសចិន ប្រទេសជប៉ុន ប្រទេសកូរ៉េ និងប្រទេសយួនជាដើម គ្មានវិស័យណាមួយ ដែលគេមើលឃើញថា ប្រទេសខ្មែរជាប្រទេសមានឯករាជ្យពេញបរិបូរនោះ ដូចជា សេដ្ឋកិច្ចជាតិ កងទ័ពជាតិ សិក្សាធិការអប់រំជាតិ រដ្ឋបាលជាតិ ជាពិសេសវិស័យជនអន្តោប្រវេសន៍ខុសច្បាប់ជាតិយួន បានចូលមករស់នៅក្នុងស្រុកខ្មែរជាច្រើនលាននាក់ដោយសេរីពេញច្បាប់ ព្រមទាំងបញ្ហាព្រំដែនដែលជនជាតិខ្មែរមើលឃើញថា ជនជាតិយួន និងសៀម បានរំលោភបំពានយកបានជាស្រេចតាមតែអំពើចិត្ត។

បើសិនណាជាប្រទេសណាមួយត្រូវបានប្រទេសដទៃណាមួយលើកទ័ពចូលឈ្លានពាន ហើយត្រួតត្រា រួចហើយតែងតាំងក្រុមមេដឹកនាំមួយឱ្យដឹកនាំជំនួស ក្រោមការបង្គាប់បញ្ជានៃកងទ័ព និងអ្នកជំនាញការ ទីប្រឹក្សាប្រទេសនោះ ដូច្នេះពុំអាចចាត់ទុកក្រុមមេដឹកនាំប្រទេសនោះ ជាឯករាជ្យពេញបរិបូរទៅបានទេ។ ម្ល៉ោះហើយក្រុមមេដឹកនាំតែងតាំងនេះ ត្រូវតែប្រើប្រាស់គ្រប់វិធានការដើម្បីតម្រូវចិត្តចៅហ្វាយនាយឱ្យតែខ្លួនឯងបានកាន់អំណាចជារៀងរហូតអស់មួយជីវិត។ ទោះបីជាការដឹកនាំនោះប្រកបដោយអគតិ អយុត្តិធម៌ ប៉ះពាល់ដល់អាយុជីវិតប្រជាជាតិ និងប្រទេសយ៉ាងណាក៏ដោយ ក៏មេដឹកនាំតែងតាំងនោះ ពុំអាចឈរនៅក្នុងជួរជាមួយជនជាតិរបស់ខ្លួនបានឡើយ ។

ដោយហេតុនេះហើយ បានជាក្រុមមេដឹកនាំនេះ ប្រព្រឹត្តធ្វើតែអំពើទុច្ចរិត ពុករលួយ ចាប់ចង រហូតសម្លាប់ចោលនូវជនជាតិរបស់ខ្លួនឯង ដោយគ្មានការអាណិតអាសូរទាល់តែសោះ ។

ចំណែកជនជាតិអន្តោប្រវេសន៍ខុសច្បាប់ គេនាំបញ្ចូលមកឱ្យរស់នៅយ៉ាងស្រួលសប្បាយរីករាយឱ្យស្របទៅតាមច្បាប់ទាំងអស់។

សេចក្តីសន្និដ្ឋាន :

ឯករាជ្យពេញបរិបូររបស់ប្រទេសកម្ពុជា នាសព្វថ្ងៃនេះ ពុំអាចចាត់ទុកថា ជាឯករាជ្យពិតប្រាកដបានទេ មានន័យថា ប្រទេសកម្ពុជាត្រូវបាត់បង់នូវឯករាជ្យអស់ទៅហើយ ដូចគ្នាប្រទេសខ្មែរកាលពីនៅក្រោមអំណាចអាណានិគមបារាំងកាលពី៥៣ឆ្នាំមុននោះទៅវិញទេ ពីព្រោះប្រទេស និងជនជាតិខ្មែរ សព្វថ្ងៃដែលកំពុងរស់នៅក្រោមអំណាចអាណានិគម និយមថ្មីយួនវៀតណាមសង្គមនិយម ដែលបានប្រើកលល្បិចរសបច្បាប់មួយ អាចបន្លំក្លែងក្លាយខ្លួនឱ្យ ដូចជាជនជាតិខ្មែរបេះបិទ និងប្រើវិធីចិត្តសាស្ត្រដ៏ល្អប្រពៃបោកបញ្ឆោតមតិជាតិខ្មែរ និងអន្តរជាតិឱ្យមើលឃើញ និងយល់ដឹងថា មេដឹកនាំខ្មែរ ដែលតែងតាំងដោយយួនហាណូយនេះ គឺពិតជាជាតិសាសន៍ខ្មែរ ហើយកំពុងតែគ្រប់គ្រងត្រួតត្រា ដឹកនាំប្រទេស និងជនជាតិខ្លួនឯងជាពិតប្រាកដទៅវិញ ដូចសុភាសិតខ្មែរបានពោលថា :

"ឃើញដំរីស្លាប់ នាំគ្នាយកចង្អេរទៅក្រុម" ។

សិទ្ធិមនុស្ស

១- សិទ្ធិមនុស្សពិតនៅក្នុងលោក មនុស្សតែងស្វែងរកចង់បានណាស់
សិទ្ធិមនុស្សនេះជួយបំផ្លាស់ ឱ្យមនុស្សស្គាល់ច្បាស់ភាពរុងរឿង ។
២- សិទ្ធិមនុស្សល្អថ្លៃឧត្តម មនុស្សតែងខិតខំដោយព្រមព្រៀង
សិទ្ធិមនុស្សជួយលើកតំកើង ឱ្យមនុស្សបានថ្កើងហើយថ្លៃថ្នូ ។
៣- សិទ្ធិមនុស្សកើត ព្រោះដោយសារ មនុស្សតាំងប្រាជ្ញាខំតស៊ូ
សិទ្ធិមានដោយត្រូវប្តូរ មនុស្សទ្រាំមិនថយទើបបានជ័យ ។
៤- សិទ្ធិមនុស្សខ្លះត្រូវបំបិទ ពីមនុស្សមានចិត្តកាចព្រៃផ្សៃ
សិទ្ធិមនុស្សនេះស្ថិតក្នុងដៃ មេកាចអប្រិយ៍គ្មានសីលធម៌ ។
៥- សិទ្ធិមនុស្សត្រូវជនទៀតត្រង់ ឆន្ទះអាចអង់មាំមួនល្អ
សិទ្ធិមនុស្សថ្លៃថ្លាបវរ នាំគ្នាក្រោកឈរហើយទាមទារ ។
៦- សិទ្ធិមនុស្សជាសភាពពិត មនុស្សរតូវមានសិទ្ធិគ្រប់ៗគ្នា
សិទ្ធិមនុស្សនេះដែលប្រជា ពលរដ្ឋត្រូវការជួយជីវិត ។
៧- សិទ្ធិមនុស្សថ្កើងព្រោះមេនាំ មេមានឧត្តមមេត្រីចិត្ត
សិទ្ធិមនុស្សច្បាស់ត្រូវតែស្ថិត ក្នុងដៃពិសិដ្ឋខ្មែរទាំងអស់ ។
៨- សិទ្ធិមនុស្សមានភាពរឹងមាំ ជាភាពឧត្តមល្អឥតខ្ចោះ
សិទ្ធិមនុស្សពិតជារបស់ ពលរដ្ឋស្ម័គ្រស្មោះទាំងប្រទេស ។
៩- សិទ្ធិមនុស្សជាអំណាចធំ ជាផ្លូវដឹកនាំផុតជាន់ជិះ
សិទ្ធិមនុស្សខ្លាំងហើយពិសេស នាំខ្មែរឱ្យចេះមានប្រាជ្ញា ។
១០-សិទ្ធិមនុស្សមានប្រៀបដូចអាវុធ ខ្លាំងក្លាបំផុតជួយប្រជា
សិទ្ធិមនុស្សឈ្នះជនឫស្យា ជាមេផ្តាច់ការត្រូវរលាយ ។
១១-សិទ្ធិមនុស្សមានពិតថ្លៃថ្លា នាំជាតិរង្គាបានពណ្ណរាយ
សិទ្ធិមនុស្សពិតភ្លឺព្រោងព្រាយ នាំខ្មែរគ្រប់កាយសប្បាយអើយ ៕

ក្រុងហ្វីឡា USA ថ្ងៃទី២៧ តុលា ២០១០
ម៉ម យ៉ឹន

ចូរធ្វើចលនា!

មួយភាគបីនៃក្មេងៗ ប្រឈមមុខចំពោះបញ្ហាសុខភាពធ្ងន់ធ្ងរខ្លាំងណាស់ ដោយព្រោះតែធាត់ពេក ។ យើងអាចជួយកូនរបស់អ្នកឲ្យជៀសវៀង ជាមួយនឹង :

- ការចូលជាសមាជិកនៅមណ្ឌលហាត់ប្រាណ
- អត្ថប្រយោជន៍ Weight Watchers® របស់យើង (សំរាប់ក្មេងៗ អាយុ 10+)
- ការប្រឹក្សាខាងអាហារមានជីវជាតិ

CHIP បាននាំមកជូនអ្នកដោយ KidzPartners មានផ្តល់ការធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ ឬថោកថ្លៃ សំរាប់ក្មេងៗ និងក្មេង ជំទង់ៗ ដែលគ្មានការធានារ៉ាប់រង ។ ថែមទាំងអត្ថប្រយោជន៍ដែល អាចនាំឲ្យមានសុខភាពល្អ អស់មួយជីវិត ។

ចូរដាក់ពាក្យសុំនៅថ្ងៃនេះ!
1-888-888-1211
TTY 1-877-454-8477

chip Pennsylvania's Children's Health Insurance Program
យើងរ៉ាប់រងក្មេងៗទាំងអស់។
www.chipcoverspakids.com

KidzPARTNERS
គំរោងសំរាប់ក្មេងៗរបស់ HEALTH PARTNERS
www.kidzpartners.com

ស្ត្រីខ្មែរដំបូងបង្អស់ដែលបានធ្វើដំណើរពីប្រទេសបារាំងមកភ្នំពេញតាមផ្លូវគោក

(តពីលេខមុន)

ដោយ : ពិន នារីពិទូ

...ទឹកដីដ៏ធំធេងរបស់ប្រទេសចិន ជាប់ចំណាត់ថ្នាក់ទីបួននៅលើពិភពលោកបន្ទាប់ពីប្រទេសរុស្ស៊ី កាណាដា និងសហរដ្ឋអាមេរិក និងមានប្រជាជនច្រើនជាងគេលំដាប់ពិភពលោកក្នុងអំឡុងពេល៣០ឆ្នាំនេះ បន្ទាប់ពីបានប្រែក្លាយរចនាសម្ព័ន្ធរបស់ខ្លួនពីទីផ្សារផែនការមកជាសេដ្ឋកិច្ចទីផ្សារសេរីដែលបានស្រូបយកអ្នកវិនិយោគទុនបរទេសជាច្រើនធ្វើឱ្យប្រទេសនេះមានសន្ទុះសេដ្ឋកិច្ចខ្លាំងក្លានៅអាស៊ីភាគអាគ្នេយ៍ ប៉ុន្តែចំណូលធៀបនឹងមូលធននៅមានកំរិតទាបនៅឡើយ ក្នុងឆ្នាំ២០០៩ ប្រទេសនេះបានក្លាយជាមហាអំណាចសេដ្ឋកិច្ចធំទីពីររបស់ពិភពលោកបន្ទាប់ពីសហរដ្ឋអាមេរិក។ អ្នកធ្វើដំណើរផ្សងព្រេងទាំងពីរ គឺអ្នកអង្គម្ចាស់ ស៊ីលវីយ៉ា និង អូរ៉េលី (Sylvia និង Aurélie) បានចំណាយពេលអស់មួយថ្ងៃឆ្លងកាត់ខេត្ត Datong គយគន់ទេសភាពព្រមទាំងរបៀបរស់នៅនៃប្រជាជននៅទីនោះដែលកំពុងប្រកបរបរធ្វើចំការ។ ថ្ងៃស្អែកក៏បានចេញដំណើរឆ្ពោះទៅទីក្រុងប៉េកាំង Beijing ដែលជារាជធានីរបស់ប្រទេសចិន និងជាទីក្រុងប្រវត្តិសាស្រ្តដ៏ល្បីល្បាញជាយូរលង់មកហើយតាំងពីសម័យមុន នៅពេលដែលអ្នកទេសចរណ៍បានឈានជើងចូលក្នុងទឹកដីនៃប្រទេសចិន ម្នាក់ៗសង្ឃឹមថានឹងបានឃើញផ្ទាល់ភ្នែកនូវកេរ្តិ៍ដំណែលវប្បធម៌ដែលបានបន្សល់ទុកតាំងពីសម័យបុរាណរហូតមកទល់បច្ចុប្បន្ននេះ គឺការទស្សនា GreatWall បានទាក់ទាញចំណាប់អារម្មណ៍អ្នកទេសចរណ៍គ្រប់គ្នាឱ្យចូលទស្សនាទីក្រុងនេះរាប់ពាន់នាក់ក្នុងមួយឆ្នាំៗ។ អ្នកអង្គម្ចាស់ស៊ីលវីយ៉ា និង អូរ៉េលី (Sylvia និង Aurélie) បានឆ្លងកាត់ទីក្រុងប៉េកាំង Beijing ដែលរំពឹងថានឹងបានទៅទស្សនា GreatWall ដែរ ដោយបើកបរនៅតាមផ្លូវជាតិពោរពេញទៅដោយចរាចរណ៍កកស្ទះ។ ក្រោមភ្លៀងរលឹមតិចៗអ្នកទាំងពីរបានដើរនៅលើផ្លូវតូចក្បែរព្រះបរមរាជវាំងដ៏ធំស្កឹមស្កៃ និងដើរមើលការតាំងលក់របស់របរសិប្បកម្មក្រោមពន្លឺភ្លើងតាមបែបបុរាណចិន បន្ទាប់មកបានបោះជំហានមកដល់តូបលក់អាហារយ៉ាងសាមញ្ញដែលដាក់លក់យ៉ាងច្រើនស្ទេកស្ទះនៅតាមផ្លូវព្រមទាំងបានភ្លក់នូវរសជាតិអាហារយ៉ាងឈ្ងុយឆ្ងាញ់និងមានតំលៃថោកសមរម្យ។ ក្រោយមកបានឈប់នៅហាងតែមួយកន្លែង ដើម្បីសំរាលភាពហត់នឿយក្នុងការដើរអស់ពេញមួយថ្ងៃ ព្រមទាំងទស្សនាការនូវសម្តែងរបាំប្រពៃណីចិន គួរជាទីចាប់អារម្មណ៍។ បន្ទាប់ពីដើរលំហែរកាយរួចមកពួកគេបានត្រឡប់ទៅ Beijing វិញដើម្បីទៅទស្សនា GreatWall ដោយធ្វើដំណើរតាមរថយន្តក្រុង ហើយបន្តដំណើរដោយថ្មើរជើងមកដល់គោលដៅ នៅពេលយប់ពួកគេក៏បានបញ្ឈប់ដំណើរនៅក្នុងភោជនីយដ្ឋានមួយ ដែលមានអាហារពិសេស គឺទាខ្វៃជាមួយបន្លែ និងទឹកជ្រលក់ ដែលជាអាហាររបស់ជនជាតិចិន។ ពួកគេបានបន្តដំណើរតាមដងវិថីដែលមានមនុស្សម្នាអ៊ូអរទស្សនាការដាក់តាំងលក់របស់របរអនុស្សាវរីយ៍គ្រប់ប្រភេទ និងម្ហូបអាហារនានា។ អស់រយៈពេលបីថ្ងៃនៅក្នុងទីក្រុងប៉េកាំង ពួកគេបានបន្តដំណើរឆ្ពោះទៅ Dezhou នៅតាមផ្លូវអ្នកទាំងពីរបានបង់ពន្ធផ្លូវគ្រប់កន្លែងដែលចេះតែកើនតំលៃឡើងផងសំណាងល្អដោយប្រេងឥន្ធនៈនៅតំបន់នោះមានតំលៃថោកសមរម្យ។ ពួកគេបានឈប់សំរាកដើម្បីប្តូរគ្រឿងបន្លាស់រថយន្តដូចជាតំរងខ្យល់ និងប្រេងឥន្ធនៈ ប៉ុន្តែមិនអាចប្តូរបាន ដោយសារសំរាប់រថយន្តម៉ាកតូយូតា Toyota RAV4 នៅក្នុងប្រទេសនេះពិបាកក្នុងការរកគ្រឿងបន្លាស់ដោយគេប្រទះឃើញរថយន្តម៉ាកនេះដោយកំរ។ បន្ទាប់ពីបើកបរអស់ពេលកន្លះថ្ងៃពួកគេបានមកដល់ Dezhou នាពេលល្ងាច។

(សូមរង់ចាំអានបន្តនៅលេខក្រោយទៀត)

ហាងខ្មែរជួសជុលរថយន្ត
បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ
Rathe´s Auto Service

State and Emission
Inspaction General
Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY

Rathe's Auto Service
2153292418 · ហាងជួសជុលរថយន្ត · CELL2154316376
5105 N. 2ND ST. PHILA.,PA 19120

- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកំរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

FREE Shipping with Your online Order

Fantasy Printing Co., *LLC.*
1243 Vine Street (13th & Vine St) - Philadelphia, PA 19107
Tel. 215-569-3744 • Fax. 215-569-3788
email: Fantasyprinting@comcast.net
Open Mon.-Fri. 10-6 • Sat. & Sun by Appt.

view sample and order online at
www.FantasyPrintingLLC.com

Print, Design & Typeset in English, Cambodian, Chinese, Vietnamese, Korean & Japanese

- Business Cards
- Restaurant Menu
- Wedding Invitations
- Envelopes / Tickets
- Brochures / Flyers / Envelopes
- Calendars
- Invoices / Gift Certificates
- Banners / Posters
- Signage

បោះពុម្ព-គ្រោងគំរូ-និងផ្ចិតអក្សរភាសាអង់គ្លេស ខ្មែរ ចិន វៀតណាម កូរ៉េ និងជប៉ុន

- ប័ណ្ណអស័យដ្ឋាន
- តារាងម្ហូបភោជនីយដ្ឋាន
- ប័ណ្ណអញ្ជើញមង្គលការ
- ស្រោមសំបុត្រ/ប័ណ្ណលក់សំបុត្រ
- លិខិតបត់ជាសៀវភៅ/ខិតប័ណ្ណលាត
- ប្រក្រតិទិន
- ប័ណ្ណទាប្រាក់គណនេយ្យ/ប័ណ្ណឱ្យរង្វាន់
- ផ្ទាំងបដារ/ ផ្ទាំងរូបខ្នាតធំ
- ផ្លាយដាក់មុខហាង

"គុណភាពខ្ពស់តម្លៃសមរម្យ"

"Superior Quality at Affordable Prices"

50% OFF
1000 Full Color Business Cards
only $47.50
reg. $95.00
(FREE SHIPPING)
on 14-16 pt coated stock with / without UV coating
expires 11/30/2010

20% OFF WEDDING INVITATIONS
View & order online at www.fantasyprintingLLC.com
expires 11/30/2010

5000 Full Color Post Cards
(4x6, 2 side Full Color)
only $250
(FREE SHIPPING)
expires 11/30/2010

អាថ៌កំបាំង និងសិល្បៈនៃជីវិត
SECRET AND ART OF LIVING

(តមកពីលេខមុន)

រៀបរៀងដោយ

លោក ម៉ៅ ច័ន្ទសំណាំ

(ក) កុងស្សនិសបរិសុទ្ធ

វត្ថុមានជាអនន្ត :

ពេលដែលមនុស្សស្លាប់ទៅ រូបកាយ ពិភពផ្លូវចិត្ត របស់មនុស្ស (លំហូរគំនិត ប្រតិកម្ម អាត្មា។ល។) ក៏រលាយបាត់ទៅ ពីព្រោះវាជាផ្នែកនៃចរិក "ដែលមានទំនាក់ទំនង" ប៉ុន្តែ កុងស្សនិសបរិសុទ្ធ ឬជីវិតដែលមានចរិកជាដាច់ខាត និងជាអនន្ត នៅតែបន្ត អត្ថិភាព ប្រៀបដូច H_2O ដែលខ្ញុំបានរៀបរាប់ពីមុនមកស្រាប់។ ជីវិតបន្តទៅតាមរូបភាពបែកខ្ញែក ដូចជា ធាតុទាំង៥ ទឹកដី ភ្លើង ខ្យល់ លំហរ និងថាមពលនានា (ដែលមានក្នុងរូបកាយមនុស្ស) ក៏បែកធ្លាយជ្រាបចូលទៅក្នុងធម្មជាតិ ហើយមានអត្ថិភាពជាបន្ត។ សំនួរសួរថា តើមនុស្សអាចកើតឡើងវិញឬទេ? តើអ្វីដែលនាំឱ្យមានកំណើតជាមនុស្សមកវិញ?

ឯកសារក្នុងព្រះពុទ្ធសាសនា ក៏ដូចជាព្រហ្មសាសនា គេបានបញ្ជាក់ថា **កម្ម ឬអំពើនៃមនុស្សម្នាក់ៗ** វាជាគ្រាប់ពូជ វាកម្លាំងជំរុញឱ្យមនុស្សយើងត្រឡប់មកកើតជាមនុស្ស ឬជាអ្វីផ្សេងទៀត (ជាសត្វក៏អាចមាន)។

តើកម្មជាអ្វី? ដូចដែលខ្ញុំបានពិពណ៌នាក្នុងវត្ថុកុងស្សនិសនៅពេលដឹងខ្លួនស្រាប់។ បាតុភូតទទួលឥទ្ធិពលពីខាងក្នុងម៉េម៉័រនេះ ក្នុងភាសាសាសនា គេហៅថា **កម្ម** Karma គឺជាគំនរនៃអំពើ (ទាំងល្អ ទាំងអាក្រក់) ប្រព័ន្ធ និន្នាការ ការចងចាំ ការពិសោធន៍ពីអតីតកាល ដែលមនុស្សយើងម្នាក់ៗឆ្លងកាត់ (ក្នុងជាតិនេះ ឬជាច្រើនជាតិកន្លងមក)។ ទ្រឹស្តីសាសនាបាបញ្ជាក់ថែមទៀតថា កម្មនេះ គេប្រៀបដូចជាគ្រាប់ពូជដែលដេកសំងំក្នុងមនុស្សយើងម្នាក់ៗ វារង់ចាំតែពេលវេលានឹងផុះចេញជាផ្លែផ្កាប៉ុណ្ណោះ ។ មើលចុះគ្រាប់ពូជដើមពោធិ៍ វាមានទំហំប៉ុនចុងចង្កឹះ លុះដល់វាធ្លាក់ដល់ដីលក្ខខណ្ឌជុំវិញអំណោយផល វាបានក្លាយទៅជាដើមពោធិ៍ដ៏ធំស្កឹមស្កៃ (នេះជាច្បាប់ធម្មជាតិ បាតុភូតនេះមានពិតជាក់ស្តែង)។ កម្មខ្លះចេញរូបរាងនៅពេលបច្ចុប្បន្ន ខ្លះទៀតនៅរង់ចាំឱកាសនឹងបញ្ចេញនូវសកម្មភាព បើបរិដ្ឋានអំណោយឱ្យ ឬពេលវេលាទុំជោ (External stimulus)។ កម្មនេះ អន្ទោលតាមប្រាណមនុស្សម្នាក់ៗ ប្រៀបដូចស្រមោល និងរូបកាយនរណា ប្រព្រឹត្តអ្នកនោះនឹងទទួលចៀសពុំរួចឡើយ Human destiny ។

វត្ថុ សំភារៈ និងបាតុភូតទាំងអស់ ដូចជា មនុស្ស សត្វ រុក្ខជាតិ សីលា ឧស្ម័ន ផ្លាស់ប្តូររូបភាពពីមួយទៅមួយ ធ្វើចលនាគ្រាប់បែបយ៉ាង អាស្រ័យដោយមានថាមពលធម្មជាតិ។ ឧទាហរណ៍ ពន្លឺព្រះអាទិត្យដែលជាថាមពលសកលចែងចាំមកលើផែនដី រុក្ខជាតិ សត្វ បណ្តាលឱ្យរីកធំធាត់។ មនុស្សត្រូវហូបចំណី បន្លែ ត្រី សាច់ (ថាមពល) បញ្ចូលទៅក្នុងខ្លួនសំរាប់មានកម្លាំងធ្វើការសព្វយ៉ាង ប្រៀបដូចជារថយន្តត្រូវការប្រេងសាំង ដើម្បីអាចចលនាទៅមុនបាន។ ដូច្នេះ នៅពីក្រៅបាតុភូតផ្លាស់ប្តូររូបភាពប្រភេទពីមួយទៅមួយអាស្រ័យដោយកម្លាំងថាមពលនេះ។

មើលចុះ លំហូរគំនិត ប្រតិកម្ម ការរំជើបរំជួលចិត្ត ទំនោរ ម៉េម៉័រ ទាំងអស់នេះ សុទ្ធតែជារូបភាពនៃថាមពលទាំងអស់។ គំនិតវាជារូបភាពនៃការប្រើប្រាស់ថាមពលក្នុងរូបកាយ បើរូបកាយហេវហត់ យើងគិតអ្វីលែងបានទៀត។ កំហឹងបើវាសំដែងចេញមកក្រៅ វាអមដោយ ចំហាយកំដៅភាយៗ ចលនាញាប់ញ័រខ្លួនប្រាណ (នេះជាការកំរើកនៃថាមពល)។ ម៉េម៉័រដែលដក់ជាប់ក្នុងខ្លួនមនុស្ស **ជារូបភាពថាមពលបង្កក** (ឬកម្លាំងកម្ម)ម វារង់ចាំពេលវេលាបញ្ចេញផ្លែផ្កា។ ពេលមនុស្សស្លាប់ថាមពលបង្កកនេះ ពុំបាត់ទៅណាទេ **វានឹងបន្តដំណើរនៅលើវិថីនៃជីវិតថ្មីមួយទៀត** ។ ធម្មជាតិគេមាន ច្បាប់កំណត់ ច្បាប់ឆក់ទាញតាមឋានានុក្រម Law of attraction ។ ថាមពលបង្កកនីមួយៗ មានគុណភាព មានអត្តចរិកដោយឡែកៗ (អាក្រក់ ល្អ ខ្ពស់ទាប មានកុសលអត់កុសល មានបុណ្យ មានបាប)។ ធម្មជាតិកណត់វិថីឱ្យថាមពលបង្កកនីមួយៗ ឆក់ទាញយោងទៅកំណើតថ្មី តាមគុណភាពរៀងៗខ្លួន មានន័យថា បើថាមពលបង្កកជោគជាំដោយកម្មក្រាស់ ភាពខ្មៅងងឹត មានបាបច្រើន នោះវានឹងឆក់ទាញទៅកាន់ដៃគូររបស់គេ ពោលគឺទីថោកទាប ទីអពមង្គល។ បើអកុសលនឹងញ៉ាំងឱ្យកើតនៅទីខ្ពង់ខ្ពស់ ទីសុខសាន្ត ទីសប្បាយរីករាយ។ ក្នុងធម្មជាតិយើងពិនិត្យឃើញថា បើអ្នកយកគ្រាប់ស្វាយពុំសែនទៅបណ្តុះដាំ វានឹងកើតបានជាដើម មែក ស្លឹក ផ្លែស្វាយពុំសែនពុំខានឡើយ នេះជាដំណើរកំណត់ញែកបំបែករបស់ធម្មជាតិ។

លុះរូបកាយថ្មីចាប់បដិសន្ធិហើយ គ្រាប់ពូជកម្ម (ថាមពលបង្កក) គេរង់ចាំឱកាសបញ្ចេញផ្លែផ្កាមកក្រៅ ជានិន្នាការ ជាចំណង់ពីក្នុងមក (ដែលយើងមនុស្សធម្មតា ពុំអាចយល់រកមូលហេតុដើមឃើញ។ យើងអាចសង្កេតឃើញឧទាហរណ៍ខ្លះៗ ក្នុងជីវិតមនុស្សរស់នៅ ខ្ញុំសូមលើកបញ្ជាក់ដូចតទៅ :

ចៅស្រីរបស់ខ្ញុំអាយុទើបតែបាន២ឆ្នាំ ទើបតែចេះដើរ រាំបង្វិលខ្លួនយ៉ាងប៉ិនប្រសប់។ ពេលខ្ញុំស្តីបន្ទោស វា១ខ្ទប់មុខពួនយំម្នាក់ឯងដូចមនុស្សចាស់។ ប៉ុន្តែលុះចំរើនធំបន្តិចមក វាភ្លេចអស់ទំនោរចាស់ពីអតីតជាតិ ប្រហែលដោយសារម៉េម៉័រថ្មីចាប់ផ្តើមមានឥទ្ធិពលគ្របដណ្តប់ ។

នៅសហរដ្ឋអាមេរិក មានក្មេងប្រុសម្នាក់ កើតមកដឹងជាតិថាខ្លួនជាអតីតអ្នកបើកយន្តហោះចម្បាំងនាសង្គ្រាមលោក វាបានស្លាប់ដោយយន្តហោះត្រូវគេបាញ់ធ្លាក់។ លុះធំចេះនិយាយ វារាយរាប់ប្រាប់ម្តាយឪពុកវាយ៉ាងលំអិត។ វាចូលចិត្តលេងល្បែងនានាទាក់ទងនឹងយន្តហោះ។ ពេលមួយនោះ ម្តាយឪពុកនាំវាទៅមើលយន្តហោះពិតប្រាកដ វាហៅឈ្មោះបន្ទាស់យន្តហោះយ៉ាងច្បាស់លាស់។ (សូមទស្សនា Internet you tube-Reincarnation, past life evidence (1/2)) ។ មានរឿងដឹងកំណើតពីជាតិមុនជាច្រើន ក្នុងអិនទឺណែត ពាក្យគន្លឹះ incarnation you tube ។ ឥឡូវនេះមនុស្សមួយចំនួនកំពុងស្រាវជ្រាវ បាតុភូត "មនុស្សស្លាប់ហើយរស់ឡើងវិញដោយអច្ឆរយៈ" Near Death Experience គេចងក្រងជាសៀវភៅប្រវត្តិជាក់ស្តែង រាប់ពាន់ ម៉ឺនទំព័រ

(សូមរង់ចាំអានលេខក្រោយបន្តទៀត)

COMPUTER+ LLC
SURVEILLANCE SYSTEM, COMPUTER RETAILER, REPAIR & SERVICES

ជំនាញការខាងជួសជុលកុំព្យូទ័រ លក់គ្រឿងកុំព្យូទ័រ
និងដាក់គ្រឿងថតវីដេអូសំរាប់ការពារសន្តិសុខ

REMOTE VIEWING
Remote Monitoring, Recording, Controlling through Internet from *anywhere* at *anytime*

5709 N. 5th St., Phila, PA 19120 Open: *Mon-Sat; 10am—6:00pm*
Peter Hong Ching * Tel: (215) 276-7000 * Fax: (215) 276-7001
E-mail: peterchng_99@yahoo.com www.computerplusllc.com

ANGKOR AUTO SERVICE,INC.
ហាងជួសជុលរថយន្ត "អង្គរ"

Free Estimate

Auto Body and Maintenance

BODY WORKS
Auto glass and windshields
Auto Frame Straightening and Painting

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស៊ូរ៉ិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services

From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

លោក កឹម សុខា ក្នុងសម្ភាសិ

(តពីលេខមុន)

ដោយ : ពិន សំខុន

ពិន សំខុន : ខ្ញុំចង់ដឹងថា ហ្វីឡា កំពុងស្វែងរកធមិតើភាពប្រកបដោយធមិហ្នឹង មានកើតទេ ដូចជានៅសប្តាហ៍នេះ នៅហ្វីឡាដែលហ្មៀវនេះ?

កឹម សុខា : ខ្ញុំឃើញ លទ្ធផលដែលយើងធ្វើនេះហ្មែ គេលះបង់គ្រប់គ្នា គេមានចិត្តធមិច្រើន ហើយគេមើលឃើញផលប្រយោជន៍រួមច្រើនណាស់ហើយ បើគេគិតដល់ប្រយោជន៍ខ្លួនគេ គឺឥតជួយបានដល់ប៉ុណ្ណឹងទេ បានន័យថា ពួកគេទទួលនូវព្រះធមិមួយចំនួនហើយបានជាសុខចិត្តលះបង់ដើម្បីប្រយោជន៍អ្នកដទៃនោះ។ នៅទីនេះបានសុខហើយៗកេដឹងថា គេធ្វើនេះ ដើម្បីអ្នកក្នុងស្រុកទេ គេហ៊ានលះបង់តែទំហំនេះវា ឥតទាន់ធំនៅឡើយទេ ។ ខ្ញុំឃើញការលំបាកព្រះធមិដែលយើងអនុវត្តន៍តាមការលះបង់នោះ គឺខ្មែរក្រច្រើនណាស់ ហើយគាត់ឥតចេះប្រើប្រាស់ព្រះធមិទេ គាត់ធ្វើដោយចាំមាត់ទៅវត្ត ទៅវ៉ាអីហ្នឹង ក៏មិនយល់ដែរ គាត់ឥតបានអប់រំផ្លូវចិត្ត ហើយនាំគ្នាធ្វើតែពិធីសាសនាតែប៉ុណ្ណោះ គឺធ្វើតែសំបកក្រៅទេ។ ខ្ញុំបានកត់ចំណាំស្អីដែលខ្ញុំបានចំណេញពីវិប្បសនាមក គឺខ្ញុំមានសំណើរថ្មីមួយទៅសមាជិកបក្សដែលនឹងប្រព្រឹត្តិនៅឆ្នាំ២០១២ គឺខ្ញុំធ្លាប់និយាយក្នុងគោលនយោបាយជាតិថា "សត្រូវដែលនាំឱ្យខ្មែរមានទុក្ខ គឺអំពើឈ្លានពានរបស់បរទេស អំពើផ្តាច់ការ និងអំពើពុករលួយ" ខ្ញុំនឹងសុំកែរថា "ឫសគល់ពិតប្រាកដ ពុំមែននៅត្រឹមអំពើឈ្លានពាន អំពើផ្តាច់ការ នឹងអំពើពុករលួយតែប៉ុណ្ណោះទេ ឫសគល់វាគឺ អំពើលោភៈ ទោសៈ ឯណោះទេ"បើអ្នកដឹកនាំរំលឹងចោលអំពើ លោភៈ ទោសៈ ចេញ គឺមិនចាំបាច់ត្រូវការលុយកាក់រហូតទៅពឹងបរទេសគេមកយកទឹកដីបាននោះទេ ។ ខ្ញុំទៅវិប្បសនាទៅមើលឃើញថា អំពើដែលជាទុក្ខរបស់ខ្មែរ គឺ លោភៈ ទោសៈ មោហៈ ដែលលាក់ខ្លួនយ៉ាងជ្រៅពីក្រោយអំពើពុករលួយ ឬផ្តាច់ការឯណោះទេ ដូច្នេះត្រូវតែគាស់ឫសនោះចេញ គឺមានតែព្រះធមិទេដែលទៅគាស់វាបាន ពេលនោះយើងដោះស្រាយបញ្ហាជាតិចេញរួចហើយ បរទេសក៏លែងឈ្លានពានយើងបាន ពួកផ្តាច់ការក៏លែងជិះជាន់បាន អំពើពុករលួយក៏លែងរីកទៅបាន ហើយគាស់ផ្តាច់អ្នកណាមុនគេ គឺគាស់ផ្តាច់ថ្នាក់ដឹកនាំមុនគេ គណបក្សសិទ្ធិមនុស្សឈ្នះឆ្នោត គឺសមាជិកគណៈរដ្ឋមន្ត្រីទាំងអស់ត្រូវធ្វើវិប្បសនា ត្រូវមានព្រះធមិនៅក្នុងខ្លួន ហើយទីស្តីការគណៈរដ្ឋមន្ត្រីត្រូវរៀបចំឱ្យមានកន្លែងអង្គុយវិប្បសនាគ្រប់វត្តអារាមទាំងអស់ត្រូវតែរៀបទីកន្លែងសម្រាប់ធ្វើសមាធិវិប្បសនា ក៏ប៉ុន្តែទាល់តែពេលយើងឈ្នះទៅកាន់អំណាច ទើបធ្វើទៅបាន បើត្រឹមតែនៅជាគណបក្សតូចតាចនៅឡើយនោះធ្វើមិនទាន់បានទេ ។

ពិន សំខុន : ក្នុងរឿងជាតកត្រង់ព្រះវេសន្តរធ្វើបុណ្យដាក់ទានពីទ្រព្យសម្បត្តិ សាច់ ឈាម រហូតដល់ប្រពន្ធ កូន ខ្ញុំចាំថា ព្រះពុទ្ធពុំបានសម្រេចដល់បុណ្យទេនាជាតិនោះ ដូច្នេះការស្រឡាញ់ប្រកបដោយការទទួលខុសត្រូវនៅតែមានអត្ថន័យខ្ពស់ដដែល ខ្ញុំចង់ឱ្យន័យថា តើការស្រឡាញ់ទឹកដីប្រកបដោយការទទួលខុសត្រូវចំពោះមុខប្រជាជាតិ បន្ថយកំហឹងនឹងលទ្ធភាពសង្គ្រាមជាមួយសត្រូវ តើអ្នកនយោបាយគួរមានការប្រមូលគ្នាការពារទឹកដីដោយធមិបានដែរឬទេ?

លោក កឹម សុខា

កឹម សុខា : តាមយើងមើល១ភ្លែត ហាក់ដូចជាមើលបញ្ហាសទ្រឹស្តីព្រះពុទ្ធ យើងប្រកាន់ថាប្រទេសរបស់យើង គេប្រកាន់ថា ប្រទេសរបស់គេ វាមិនដូចទស្សនៈព្រះពុទ្ធថា ឯងនៅលើដីអញក៏នៅទៅ អញនៅទីកន្លែងឯងក៏នៅទៅ ព្រះពុទ្ធគឺអីចឹង ដើម្បីបញ្ចប់ព្រំដែននៃកម្មសិទ្ធិហ្នឹង... វគិតៗទៅខ្ញុំយល់ថា ព្រះពុទ្ធគ្រាន់តែបង្ហាញផ្លូវដ៏ជ្រៅបំផុតទេ មនុស្សដើរឥតដល់ទេ តែការតម្រង់ទៅទិសហ្នុង គឺសម្រាលឱ្យស្រាលបំផុតនៃអកុសលទាំងឡាយដែលជាគ្រឿងហ្មងសៅក្នុងខ្លួនហ្នុងតែប៉ុណ្ណោះទេ ។

ពិន សំខុន : ឥឡូវងាកមករកដំណោះស្រាយមួយដែលកំពុងជាកង្វល់ និងជាទំនាស់ ខ្ញុំឃើញរបៀបសាយនៃគណបក្ស សម រង្ស៊ី និង ទស្សនៈនៃគណបក្សសិទ្ធិមនុស្សបានមកដល់ជម្លោះមួយស្ទើរយកគ្នាជាសត្រូវទៅហើយ ក៏ប៉ុន្តែអ្នកទាំង២នៅជិតគ្នាបង្ហើយសោះ តើចំណាយនៃកម្លាំងព្រះធមិនឹងធ្វើឱ្យលោក សុខា ដោះស្រាយដោយវិធីណា?

កឹម សុខា : យើងឥតប្រកាន់ថា គណបក្សនេះជារបស់ខ្ញុំទេ តែមិនមែនបានន័យថា ទុកឱ្យគណបក្សសិទ្ធិមនុស្សស្លាប់ទេ អ្នកណាក៏ដោយ ឱ្យតែមានសមត្ថភាព គោលនយោបាយល្អ អាចថែរក្សាបានយើងឱ្យគេដឹកនាំ ការកិរិតអាណត្តិដឹកនាំទាំងនោះគឺទុកឱ្យអ្នកឯទៀត ក៏អាចដឹកនាំបានដែរ ការធ្វើតាមព្រះធមិនេះ បើលោក សម រង្ស៊ី យល់ថាគណបក្សនេះ ពុំមែនជាកម្មសិទ្ធិរបស់គាត់ដែរ ជាការងាយស្រួលបំផុត បើផ្ទុយពីនេះ ក៏មានការលំបាកក្នុងរូបរួមគ្នាដែរ ។ ខ្ញុំឃើញលោក សម រង្ស៊ី ពិចារណាត្រូវនៅលើចំណុចមួយ ដូចជា គាត់សុខចិត្តឱ្យទៅគេហើយសុខចិត្តប្តូរឈ្មោះ ហើយស្រាប់តែគេយកទៅបំផ្លាញខ្ទេចអស់ អាហ្នឹងគាត់ក៏មិនអាចធ្វើដូចនេះបានដែរ គាត់ត្រូវនាំគ្នាអង្គុយគិតថា ធ្វើម៉េចកុំឱ្យគេយកទៅបំផ្លាញបាន ដូចព្រះវេស្សន្តរអីចឹង បើសិនជាព្រះពុទ្ធលះបង់កូន-ប្រពន្ធ ហើយដឹងថា កូននឹងទៅកាន់ទីសុខសាន្ត អាហ្នឹងមិនអីទេ តែព្រះអង្គដឹងថា គេយកទៅធ្វើបាប អីចឹងព្រះពុទ្ធលោកខុស...ហើយឧបមាថា ខ្ញុំដឹកនាំឱ្យគណបក្សសិទ្ធិមនុស្សទៅចូល សម រង្ស៊ី តែដល់ចូលទៅហើយ ដោះស្រាយបញ្ហាជាតិមិនបាន នៅតែជាកម្មសិទ្ធិដដែល អីចឹងខ្ញុំធ្វើហ្នឹងវាខុស... តែបើគាត់យកទៅហើយកែទម្រង់ទាំងអស់គ្នាទៅហើយ អាហ្នឹងការមិនប្រកាន់ថាគណបក្សជារបស់ខ្ញុំហ្នឹងទើបត្រឹមត្រូវ។ *(តទៅលេខក្រោយ)*

ការិយាល័យច្បាប់

ERIK B.JENSEN P.C
A Profesional Corporation

We Handle All INJURY CASES
- Auto/Bus/Train/Motorcycle
- Slip and Fall / Workplace Accidents
- Medical Malpractice
- Nursing Home Neglect
- Dog Bites / Wrongful Death

Criminal Defense – DUI
Adult & Juvenile
Felonies / Misdemeanors / Drug Offenses
Weapons Charges / Murder / Manslaughter
Robbery / Burglary / Theft / Rape / Child Abuse
Drunk Driving / Traffic Violations
BANKRUPTCY
Sheriff Sales / Foreclosures / Repossessions
Credit Repairs / Tax Liens

FAMILY
Divorce / Support
Alimony / Child Custody
Protection From Abuse
Visitation / Adoptions
REAL ESTATE
Commercial – Residential
Buying / Selling
Settlements / Closings

BUSINESS
Contracts / Negotiations
Litigation
Start-ups / Financing
Collections
TAX PROBLEM
IRS Disputes / Tax Fraud
Audits / Liens / Levies
Tax & Estate Planning

Wills, Estates & Trusts Social Security

មានអ្នកបកប្រែភាសាខ្មែរ
Rely On Over
26 Years Of Experience

WWW.ERIKJENSENLAW.COM
we have Khmer staff

Voun Lay, BS
Marketing Coordinator
267-738-7006

FREE Consultation ERIK B. JENSEN, P.C. Attorneys At Law
215-546-4700 24 HOUR AVAILABILITY 800-522-6606
1528 Walnut St., Suite 1401 Philadelphia

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី២៩៤ ខែតុលា ឆ្នាំ២០១០

Tea Banh to Go to Bangkok For 2-Day Border Meeting

Defense Minister General Tea Banh is to travel to Thailand today for a two-day meeting on border issues, said Nem Sowath, director general of the Defense Ministry's general department of policy and foreign affairs. "Defense Minister Tea Banh will lead the defense delegation to attend the General Border Committee meeting in Bangkok," Mr Sowath said by telephone yesterday. Other members of the delegation left Wednesday, said Mr Sowath, who added that he did not know details of the meeting's agenda. The General Border Committee deals with "problems that arise along the border that [are] involved with human activities...like smuggling," said Phay Siphan, spokesman for the Council of Ministers. The Joint Border Committee, in contrast, is tasked with demarcation of the Thai-Cambodia border. The Thai Parliament on Tuesday delayed discussion of the last three JBC meeting minutes. Thai and Cambodian troops have clashed sporadically at the disputed border near Preah Vihear temple since its 2008 listing as a World Heritage Site. *(Eang Mengleng and Clancy McGilligan)*

លោក ទៀ បាញ់ នឹងទៅបាងកកចូលរួមប្រជុំ

ដោយ អៀង ម៉េងឡេង និង CLANCY MCGILLIGAN

THE CAMBODIA DAILY

លោក ណែម សូវ៉ាត អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការនយោបាយ និងបរទេសបានថ្លែងថា លោកឧត្តមសេនីយ៍ ទៀ បាញ់ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងធ្វើដំណើរទៅ ប្រទេសថៃ នៅថ្ងៃនេះសម្រាប់កិច្ចប្រជុំរយៈពេល ២ថ្ងៃស្តីពីបញ្ហាព្រំដែន ។ លោក សូវ៉ាត បានថ្លែងតាមទូរស័ព្ទកាលពីម្សិលមិញ ថា "លោករដ្ឋមន្ត្រី ទៀ បាញ់ និងដឹកនាំ គណៈប្រតិភូការពារជាតិទៅចូលរួម កិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ ក្នុងក្រុងបាងកក" ។ លោក សូវ៉ាត បានថ្លែងថា "សមាជិកផ្សេងទៀតនៃគណៈប្រតិភូនេះបានចាកចេញកាលពីថ្ងៃពុធ ។ លោកបានបន្ថែមទៀតថា លោកមិនដឹងសេចក្តីលំអិតអំពីរបៀបវារៈក្នុងកិច្ចប្រជុំនេះទេ ។ លោក ផៃ ស៊ីផាន អ្នកនាំពាក្យរបស់ទីស្តីការគណៈរដ្ឋមន្ត្រីបានថ្លែងថា គណៈកម្មាធិការព្រំដែនទូទៅនេះដោះស្រាយ "បញ្ហាដែលកើតឡើងនៅតាមបណ្តោយព្រំដែនដែលទាក់ទងនឹងសកម្មភាពមនុស្ស... ដូចជាការរត់ពន្ធជាដើម ។ ផ្ទុយទៅវិញគណៈកម្មាធិការព្រំដែនរួមមានភារកិច្ចបោះបង្គោលព្រំសីមានៅតាមព្រំដែនកម្ពុជា-ថៃនោះ ។ កាលពីថ្ងៃអង្គារសភាថៃ បានពន្យាពេលក្នុងការពិភាក្សាអំពីកំណត់ហេតុប្រជុំគណៈកម្មាធិការព្រំដែនរួមចំនួន៣ចុងក្រោយ ។ ទាហានថៃនិងទាហានកម្ពុជាបានប៉ះទង្គិចគ្នាយូរៗម្តងនៅឯព្រំដែនដែលមានវិវាទក្បែរប្រាសាទព្រះវិហារតាំងពីការចុះបញ្ជីជាទីកន្លែងបេតិកភណ្ឌពិភពលោកឆ្នាំ២០០៨មក ៕

Kratie Man Murder His Wife With Machete, Kills Self

A 30-year-old Kratie man on Wednesday hacked his wife to death with a machete before stabbing himself in the chest with a small kitchen knife, and when he did not immediately die, hanged himself, provincial police said yesterday. Tok Loeus allegedly attacked Chour Thea, 35, at home in Prek Prasap district's Prek Prasap commune after she refused to reconcile with him following a recent separation, deputy commune police chief Yin Chanheng said. Thim Narin, provincial coordinator for local rights group Adhoc, said that the victim´s father had said the couple's marriage broke down becuase Mr Loeus was repeatedly violent to Ms Narin, "The villagers were afraid of him," added Ms Narin. The alleged murder follows recent spate of brutal domestic violence attacks. Last Sunday saw two people douse their spouses with gasoline and set them alight in separate attacks in Banteay Meanchey and Kompong Cham provinces. Both victims died from their injuries. And in Seem Reap province last Saturday, a man killed his 6-year-old daughter and seriously injured his wife in a machete attack. (Phok Dom)

បុរសនៅក្នុងខេត្តក្រចេះកាប់ប្រពន្ធរហូតដល់ស្លាប់

ដោយ ភោគ ដម

THE CAMBODAI DAILY

ប៉ូលិសខេត្តបាននិយាយកាលពីថ្ងៃម្សិលមិញថា កាលពីថ្ងៃពុធបុរសអាយុ៣០ឆ្នាំម្នាក់ នៅខេត្តក្រចេះបានកាប់ប្រពន្ធរបស់ខ្លួនរហូតដល់ស្លាប់ដោយកាំបិតផ្គាក់មួយមុនពេលចាក់ទ្រូងខ្លួនឯងដោយកាំបិតចិតបន្លែតូចមួយ ហើយនៅពេលដែលខ្លួនមិនទាន់ស្លាប់ភ្លាម គាត់បានចងកសម្លាប់ខ្លួន ។ លោក យិន ច័ន្ទហ៊ាង នាយរងប៉ុស្តិ៍បានថ្លែងថា ឈ្មោះ តុក លើស តាមចោទថា បានកាប់ឈ្មោះ ជូរ ធា អាយុ៣៥ឆ្នាំ ស្នាក់នៅក្នុងឃុំព្រែកប្រសប់ ស្រុកព្រែកប្រសប់ បន្ទាប់ពីអ្នកស្រីបានបដិសេធមិនព្រមជួបជុំជាមួយខ្លួនវិញ បន្ទាប់ពីចែកផ្លូវគ្នាថ្មីៗនេះ ។ លោកស្រី ទឹម ណារិន អ្នកសម្របសម្រួលរបស់អង្គការសិទ្ធិមនុស្សអាដហុកក្នុងស្រុកនៅខេត្តនេះ បានថ្លែងថា ឪពុករបស់ជនរងគ្រោះបាននិយាយថា អាពាហ៍ពិពាហ៍របស់គូរស្វាមីភរិយាទាំង២នេះបានបែកបាក់ ពីព្រោះលោក លើស បានប្រើអំពើហិង្សាជាច្រើនលើកទៅលើប្រពន្ធ។ លោកស្រី ណារិន បានថ្លែងថា"អ្នកភូមិខ្លាចគាត់" ។ ឃាតកម្មថ្មីៗនេះ កើតឡើងបន្ទាប់ពីការកើតមានការវាយប្រហារអំពើហិង្សាក្នុងគ្រួសារដ៏ព្រៃផ្សៃដូចគ្នានេះ ។ កាលពីថ្ងៃអាទិត្យមុន មានមនុស្ស២នាក់បានយកប្រេងសាំងចាក់ស្រោចលើប្រពន្ធរបស់ខ្លួន ហើយដុតពួកគេនៅក្នុងការវាយប្រហារ ដោយឡែកពីគ្នានៅក្នុងខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ចាម ។ ជនរងគ្រោះទាំង២នាក់ បានស្លាប់ដោយសាររបួសរបស់ខ្លួន។ ហើយនៅក្នុងខេត្តសៀមរាបកាលពីថ្ងៃសៅរ៍មុនបុរសម្នាក់បានស្លាប់កូនស្រីអាយុ៦ឆ្នាំរបស់ខ្លួន និងធ្វើឱ្យប្រពន្ធរបស់ខ្លួនរងរបួសធ្ងន់ក្នុងការវាយប្រហារដោយកាំបិតផ្គាក់មួយ ៕

ដោយ : គឹម ភឿន ***(តពីលេខមុន)***

•••វីរៈសួរនាយច្រកដោយងឿងឆ្ងល់ : "ចុះបុប្ផាណែនាំក្មេងនោះយ៉ាងម៉េចបានជាអង្គការលើចោទថាបានប្រឆាំងនឹងពួកគេ? ។ ច្រកឆ្លើយដោយរហ័ស : "គាត់សុំឱ្យគណៈកម្មការវិន័យ និងសីលធម៌មេត្តាទុកឱ្យសិស្សនោះបាននៅរៀនជាធម្មតា ដើម្បីបានប្រឡងនៅដំណាច់ឆ្នាំនេះ ព្រោះនេះជាកំហុសដំបូងដែលសិស្សនោះបានប្រព្រឹត្ត ហើយជាក្តីអនុគ្រោះរបស់វិទ្យាល័យអង្គតាសោមផង។ ប្រសិនបើសិស្សនេះបានប្រព្រឹត្តលើកទីពីរ ចាំពិន័យសិស្សនេះតាមវិន័យសាលាដែលបានចែងទុកមកស្រាប់ ។ ម្យ៉ាងទៀតគណៈកម្មការវិន័យបានសុំឱ្យសិស្សនោះអរគុណចំពោះក្តីអនុគ្រោះរបស់វិទ្យាល័យ នឹងទទួលស្គាល់នូវកំហុសរបស់ខ្លួននៅមុខសិស្សទាំងអស់ក្រោយពេលគោរពទង់ជាតិនៅទីធ្លាសាលា។ សិស្សប្រុសបានធ្វើតាមការណែនាំរបស់គណៈកម្មការវិន័យ ប៉ុន្តែវាគេចសាលា ហើយរត់ចេញបាត់ពីផ្ទះតែម្តង។ ប្រហែលបីថ្ងៃក្រោយពួកវាបានមកចាប់បងបុប្ផាយកទៅសម្លាប់" ។

បរិយាកាសប្រែជាស្ងាត់ដូចស្លាប់ ឮតែសម្លេងដកដង្ហើមធំរបស់អ្នកទាំងពីរ ។ ស្រាប់តែមានទាហាននាំសារម្នាក់ចូលមកក្នុងការិយាល័យរបស់វីរៈ ហើយហុចសារមួយសន្លឹកជូនលោកអនុសេនីយ៍ឯក

- អគ្គបញ្ជាការកងទ័ពផ្ញើសារនេះមកជូនតេជអុណជាបន្ទាន់ ។ វីរៈហាក់ដូចដឹងមុនជាស្រេចន័យនៅក្នុងសារនោះ គេក៏យកមកអានភ្លាមក៏ដឹងថាជាសាររបស់បងធម៌របស់គេផ្ញើមក :

"ដឹងថាឯងមានការឈឺចាប់ខ្លាំង អ្នកគ្រូបុប្ផាស្លាប់នៅម៉ោង៨ព្រឹកស្អែក១៧.០៥.១៩៧៣ បងនាំឧទ្ធម្ភាចក្រទៅទទួលឯងមកចូលរួមពិធីបុណ្យរំលាយសពឯភ្នំពេញ អាចអញ្ជើញភ្ញៀវមកចូលរួមប្រហែល១០នាក់។ កុំឈឺចាប់ពេក...

ពីបង អ្នករួមប្រយុទ្ធរបស់ឯង : អ៊ុំសាវុឌ្ឍ

អានចប់ភ្លាមវីរៈសម្លឹងមុខច្រកដោយក្រៀមក្រំ : " ស្អែកម៉ោង៨ព្រឹកឧទ្ធម្ភាចក្រមកដឹកយើងទៅភ្នំពេញចូល រួមពិធីបុណ្យបូជាសពបុប្ផា ប្អូនត្រូវទៅខំរៀនប្រឡងឱ្យជាប់ បងខំប្រឹងជួយឯងជំនួសបុប្ផា កុំបារម្ភឱ្យសោះ" ។ ច្រកឱនមុខចុះលាក់បាំងការទុក្ខព្រួយរបស់ខ្លួន ដែលគេមិនដែលធ្លាប់ជួបប្រទះឡើយក្នុងមួយជីវិតគេនេះ ។

ម៉ោង៨ព្រឹកស្អែកឡើងឧទ្ធម្ភាចក្រ២គ្រឿងបានវិលក្រឡឹងលើផ្ទៃមេឃនៃបន្ទាយបញ្ជាការកងទ័ពស្រុកតាំងគោក រួចនាំគ្នាបន្ទាបខ្លួនចុះក្នុងបន្ទាយបាត់ទៅ។ មិនយូរប៉ុន្មានយន្តទាំងពីរគ្រឿងបានហោះត្រង់ឡើងលើបង្វិលតម្រង់ទៅភ្នំពេញហើយក៏បោះពួយលឿនស្លេវទៅមុខ។

ឧទ្ធម្ភាចក្របន្ទាបខ្លួនចុះនៅក្នុងបរិវេនភូមិគ្រឹះមួយយ៉ាងស្កឹមស្កៃ ទីនេះហើយដែលកាលនៅជានិស្សិត វិរៈធ្លាប់ជូនសង្សាខ្លួនមកពីសាលារៀនថ្នាក់ពិសេសខាងគណិត និងរូបវិទ្យានាពេលយប់។ ក្តីស្នេហ៍ដ៏ផ្អែមល្ហែម និងឧត្តមបានកន្លងផុតទៅដែលវីរៈមិនស្មានថាអាចបញ្ចប់ទៅយ៉ាងខ្លោចផ្សារបៀបនេះសោះ។ ក្តីស្នេហ៍បានផ្តល់សេចក្តីសុខយ៉ាងច្រើនដល់វីរៈ ទោះបីវីរៈមិនដែលបានបោះជំហានចូលដល់ក្នុងភូមិគ្រឹះនេះម្តងណាឡើយក៏ដោយ បានតែត្រឹមជូននាងដល់មាត់របង ហើយបែរក្រោយត្រឡប់ទៅវត្តលង្កាដែលស្ថិតមិនឆ្ងាយប៉ុន្មានពីទីនោះក៏ដោយ។ ម្តងនេះបានឧទ្ធម្ភាចក្រនាំមកចុះដល់ផ្ទះនាង តែនាងបានបន្សល់ទុកនៅតែសពស្ងួកស្ងឹងគ្មានព្រលឹងទៅហើយ!។ គិតដល់ត្រឹមនេះវីរៈខំប្រឹងទប់ទឹកភ្នែក ខំទប់ក្តីខ្សឹកខ្សួលដែលកំពុងហូរស្រោចមកច្រាលពេញបំពង់កគេ។ ហើយប្រុងប្រៀបខ្លួនចុះពីឧទ្ធម្ភាចក្រដើម្បីដើរចូលទៅក្នុងរោងបុណ្យ។

លោកឧត្តមសេនីយ៍អ៊ុំសាវុឌ្ឍ នាំមុខភ្ញៀវដើរតម្រង់ទៅរោងបុណ្យ ដើរតាមក្រោយលោកឧត្តមសនីយ៍ មានវីរៈ នាយច្រក ព្រមទាំងឪពុកម្តាយធម៌របស់វីរៈ និងភ្ញៀវជិតស្និទ្ធមួយចំនួនទៀត។ ពេលដើរដល់រោងបុណ្យ វីរៈបានប្រទះឃើញជីដូនចាស់ជរាម្នាក់រត់មកឱបខ្លួនគេ ហើយយំរជើតរជក: "ចៅ! ចៅវីរៈ! មកពីយាយជាប់ជំពាក់នឹងផ្ទះសំបែងមិនព្រមតាមបណ្តាំចៅ ទើបបុប្ផាស្លាប់យ៉ាងនេះ" ។ និយាយបានតែត្រឹមនេះលោកយាយបែរជាទន់ខ្លួនរងាក ហើយដួលមកលើស្មារបស់វីរៈ។ ដឹងថាលោកយាយរន្ធត់ចិត្តខ្លាំងរហូតដល់បាត់ស្មារតី វីរៈគ្រាគាត់ទៅក្នុងគេហដ្ឋានដាក់គាត់សម្រាកលើគ្រែ ដើម្បីគក់ប្រាច់ឱ្យគាត់ដឹងខ្លួនមកវិញ។ ក្រោយមកដោយក្តីអាណិតស្រឡាញ់របស់ឪពុកម្តាយនៃគូដណ្តឹងរបស់គេ គេបានអ្នកទាំងពីរនាំទៅដុតធូបនៅមុខរូបថតរបស់សង្សាគេដែលតាំងនៅពីមុខម្ឈូសរបស់នាង។ គេមិនអាចនិយាយអ្វីឱ្យបានច្រើនទេ គ្រាន់តែបានសម្រក់ទឹកភ្នែកៈ សូមអូនបានទៅកាន់សុគ្គតិភពចុះ" ។ រួចហើយក៏ដើរតាមលោកទាំងពីរទៅកាន់រោងបុណ្យដើម្បីលោកទាំងពីរបានណែនាំឱ្យញាតិមិត្តស្គាល់ថា ជាកូនប្រសាមិនទាន់បានរៀបការរបស់គាត់ ហើយឥឡូវគាត់ទទួលស្គាល់ ដូចជាកូនរបស់គាត់ផ្ទាល់ទៅវិញ។ ឮសំដីដ៏ផ្អែមល្ហែមទាំងនេះ វីរៈកក់ក្តៅក្នុងចិត្ត ហើយកាន់តែស្រឡាញ់ និងអាណិតគាត់ខ្លាំងណាស់ទៅទៀត។

(សូមរង់ចាំអានបន្តទៅទៀតនៅក្រោយ)

ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

ប្រែសម្រួលដោយ : ពិន សំខុន (តពីលេខមុន)

·១១ តុលា : ក្រុម "កម្ពុជាប្រជាមានិត" ប្រកែកមិនទទួលសំណើររបស់ប្រធានសន្និសីទអន្តរជាតិស្ដីពីកម្ពុជា សំណើរប្រកាសតំបន់អង្គវត្តមិនឱ្យមានកងទ័ព ។ ខាងរដ្ឋាភិបាល "កម្ពុជាប្រជាធិបតេយ្យ" យល់ព្រមតាមសំណើរ ។ បេសកកម្មបច្ចេកទេសរបស់ប្រទេសឥណ្ឌា ស្នើឱ្យមានកម្មវិធីជួសជុលអង្គវត្តរយៈពេល៦ឆ្នាំ ។

·១២ តុលា : ជប៉ុនមិនព្រមចេញទិដ្ឋាការឱ្យមន្ត្រីផ្លូវការ "កម្ពុជាប្រជាមានិត" ។

·១៧ តុលា : មហាសន្និបាត អ.ស.ប អនុម័តដោយគ្មានបោះឆ្នោតលើភាពជាតំណាងកម្ពុជា ដោយ "កម្ពុជាប្រជាធិបតេយ្យ" ។

·៣០ តុលា : មហាសន្និបាទ អ.ស.ប បានបោះឆ្នោតលើសេចក្ដីសម្រេចចិត្តដូចឆ្នាំ១៩៨៣ ដោយសម្លេង ១១០ ប្រឆាំង ២២ នឹងអនុប្បវាទ ១៨ ។ នៅហ្សឺណែវ សន្និសីទ អ.ស.ប ស្ដីពីវិស័យអប់រំ បានទទួលគណៈប្រតិភូ "កម្ពុជាប្រជាធិបតេយ្យ" ។

·១៧ វិច្ឆិកា : វាយសម្រុករបស់ទ័ពវៀតណាមទៅលើជំរំ "កម្ពុជាប្រជាធិបតេយ្យ" ។ ជំរំចំពោះមុខទី១ គឺ នង ច័ន្ទ របស់លោក សឺន សាន ។

·១២ ធ្នូ : សេចក្ដីរាយការណ៍របស់ក្រុមមេធាវីអន្តរជាតិខាងផ្នែកសិទ្ធិមនុស្ស បានចោទប្រកាន់ថា វៀតណាមធ្វើទារុណកម្មលើពលរដ្ឋខ្មែរ ដែលទ័ព "កម្ពុជាប្រជាមានិត"ចាប់បាន ។

·២៤ ធ្នូ : សមាជិកព្រឹទ្ធសភាអាមេរិកាំងលោក ស្ទេហ្វាន សូឡា ទៅធ្វើទស្សនៈកិច្ចនៅភ្នំពេញ ហើយបានជួបជាមួយ ហ៊ុន សែន ។

·២៧ ធ្នូ : យៀកណាម វាយបែកជំរំរបស់លោក សឺន សាន នៅបក្សី. សុខសាន្ត និង នង សាមេត ។

·៣១ ធ្នូ : ចាន់ ស៊ី នាយករដ្ឋមន្ត្រីកម្ពុជាប្រជាមានិត ស្លាប់នៅមូស្គូ ។

ឆ្នាំ ១៩៨៥

ដើមខែមករា : យកមូលដ្ឋានទ័ពលោក សឺន សាន នៅអំពិល បាន ។ យកមូលដ្ឋានខ្មែរក្រហម នៅ ណាមយុន និង ចុងបុក ។

·១៤ មករា : ហ៊ុន សែន ត្រូវបានតែងតាំងជាប្រធានគណរដ្ឋមន្ត្រី (ជានាយករដ្ឋមន្ត្រី) ហើយនៅរក្សាតួនាទីប្រមុខកិច្ចការបរទេស ក្នុងសមាសភាពរដ្ឋាភិបាល ចាន់ សី ។

·៣ កុម្ភៈ : ប្រជុំរដ្ឋាភិបាល "កម្ពុជាប្រជាធិបតេយ្យ" នៅភ្នំម៉ាឡៃ ។

·១១ កុម្ភៈ : "កម្ពុជាប្រជាធិបតេយ្យ" ចូលរួមប្រជុំអាស៊ាន នៅបាងកក ។

·១៣ កុម្ភៈ : ទ័ពវៀតណាម ១៨.០០០នាក់ វាយបណ្ដេញក្រុមខ្មែរក្រហមបែកនៅភ្នំម៉ាឡៃ ។

·១៧ កុម្ភៈ : បើកជំរំថ្មីមួយសម្រាប់ក្រុមខ្មែរក្រហម ហៅថា ជំរំលេខ៨ ឬ Site 8 ។ ខ្មែរក្រហមឱ្យឈ្មោះថា ខាវតាង៉ុក ជាកូនភ្នំមួយនៅក្បែរនោះ ។

·ដើមខែមីនា : យកជំរំទ័ពលោក សឺន សាន FANLPK ។

·៨ មីនា : យកជំរំ តាទុំ របស់ទ័ព សីហនុនិយម បាន ។

·៩ មីនា : ប្ដូរគណរដ្ឋមន្ត្រីដ៏សំខាន់មួយរបស់ "កម្ពុជាប្រជាមានិត"

(សមាសភាពរដ្ឋាភិបាល ហ៊ុន សែន ថ្មី

– រដ្ឋាភិបាល ហ៊ុន សែន (៩ មីនា ១៩៨៥)

. នាយករដ្ឋមន្ត្រី (តាំងពីថ្ងៃ១៤ មករា ១៩៨៥) រដ្ឋមន្ត្រីការបរទេស : ហ៊ុន សែន
. ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការពារជាតិ : ប៊ូ ថង
. ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីផែនការ : ជា សុទ្ធ
. រដ្ឋមន្ត្រីមហាផ្ទៃ : ខាង សារិន
. រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងពាណិជ្ជកម្ម : ចាន់ ភិន
. រដ្ឋមន្ត្រីក្រសួងកសិកម្ម : គង់ សំអុល
. រដ្ឋមន្ត្រីឧស្សាហកម្ម : មាស សំណាង
. រដ្ឋមន្ត្រីទំនាក់ទំនងវប្បធម៌ និងសេដ្ឋកិច្ចជាមួយបណ្ដាប្រទេសសង្គមនិយម : តាង សារឿន
. រដ្ឋមន្ត្រីដឹកជញ្ជូន-គមនាគមន៍ និងប្រៃសណីយ៍ : ទា បាញ់
. រដ្ឋមន្ត្រីយុត្តិធម៌ : អ៊ុក ប៊ុនឈឿន
. រដ្ឋមន្ត្រីសុខាភិបាល : យិត គីមសេង
. រដ្ឋមន្ត្រីកិច្ចការសង្គម និងជនរងគ្រោះដោយសង្គ្រាម : ម៉ម សាប៊ុន
. រដ្ឋមន្ត្រីអប់រំជាតិ : ប៉ែន ណាវុធ
. រដ្ឋមន្ត្រីឃោសនាការ-ព័ត៌មាន និងវប្បធម៌ : ឆេង ផុន
. ប្រធានគណៈកម្មាការត្រួតពិនិត្យរដ្ឋ : ស៊ឹម កា
. រដ្ឋមន្ត្រីអមទីស្ដីការគណៈរដ្ឋមន្ត្រី : ឃុន ឈី
. នាយកខុទ្ទកាល័យនៃក្រុមប្រឹក្សារដ្ឋមន្ត្រី : អ៊ុង ផន
. នាយកធនាគារជាតិ : ចា រៀង

(តទៅលេខក្រោយ)

ពុទ្ធប្បវត្តិអមដោយរូបភាព

A Pictorrial Biography of Saky amuni Buddha

- រូបភាព និងរឿងដើមជាភាសាថៃ ដោយ គុណាប៉ាយុតា
- បកប្រែជាភាសាអង់គ្លេស ដោយ ហ្សិត .អេ.លី
- ផាត់ពណ៌ដោយ យ៉ាន់ ហ្វាលី
- បកប្រែជាភាសាខ្មែរដោយភិក្ខុ គង់ អាំ

៩៤- ថ្ងៃមួយព្រះសិទ្ធត្ថទ្រង់យាងដោយ ព្រះបាទផ្ទាល់ចាកចេញពីក្រុងរាជគ្រឹះទៅកាន់ជើងភ្នំមួយកន្លែង ដែលមានតាបសឥសីគង់នៅជាច្រើន ។ នៅតាមផ្លូវព្រះអង្គទ្រង់ឃើញធូលីដីហុយឡើងទ្រលោមធ្លាក់ចុះពីលើភ្នំ ព្រមទាំងស្នូរសន្ធឹកសំលេងជើងសត្វរត់ផង ។ ដោយចេះតែនិមន្តកាន់តែជិតទៅៗ ព្រះអង្គទ្រង់ប្រទះឃើញចៀម និងពពែមួយហ្វូងធំដែលកំពុងតែរត់តាមបណ្ដោយផ្លូវ ប្រៀបដូចជាដុំពពក ។ សត្វទាំងឡាយនេះត្រូវគេកៀរដេញសំដៅទៅទីក្រុងយ៉ាងអនោចអធ័ម ។ នៅតាមក្រោយនៃហ្វូងចៀម និងពពែនេះ មានកូនចៀមតូចមួយដើរវេរា១ខ្ចកខ្ចើច១ដោយមានការឈឺចាប់យ៉ាងខ្លាំង ជើងរបស់វាត្រូវរបួសចេញឈាមហូរសស្រាក់ ។ ព្រះមហាករុណាសិទ្ធត្ថទ្រង់ទតឃើញកូនចៀមដ៏កំសត់នេះ ហើយមេរបស់វាកំពុងដើរពីខាងមុខចេះតែក្រឡេកមើលមកកូនវានៅខាងក្រោយជានិច្ចទាំងក្ដីកើតទុក្ខក្រៀមក្រំបារម្ភព្រួយយ៉ាងជ្រាលជ្រៅចំពោះកូនតូចរបស់វា ។ ព្រះទ័យព្រះអង្គពោរពេញទៅដោយក្ដីករុណាអាណិតអាសូរពន់ពេកណាស់ ។

៩៥- ឃើញយ៉ាងវេទនាដូច្នេះ ព្រះសិទ្ធត្ថទ្រង់ចាប់បីកូនចៀមកំសត់ដែលជើងត្រូវរបួសនេះក្នុងព្រះហស្ថព្រះអង្គផ្ទាល់ រួចព្រះអង្គទ្រង់បបោសអង្អែលសើរ១ថ្នម១នៅពេលកំពុងនិមន្តតាមពីក្រោយហ្វូងសត្វនោះ ។ នៅពេលដែលព្រះអង្គទ្រង់ទតឃើញពួកអ្នកគង្វាលចៀម ព្រះទ្រង់មានព្រះបន្ទូលសួរថា "ម្នាលអ្នកគង្វាលទាំងឡាយ តើអ្នកដេញសត្វទាំងនេះទៅទីណា? ព្រោះតាមធម្មតាគេតែងតែដេញវាត្រឡប់ទៅកាន់កន្លែងក្រោលវិញនៅរាល់១ល្ងាច ចុះហេតុដូចម្ដេចបានជាអ្នកទាំងឡាយនាំគ្នាដេញវាវិលវិញក្នុងវេលាទើបថ្ងៃរសៀលដូច្នេះទៅវិញ?" ពួកអ្នកគង្វាលទាំងឡាយឆ្លើយថា "បពិត្រព្រះអង្គ ព្រះរាជាទ្រង់ប្រារព្ធពិធីបូជាយញ្ញយ៉ាងធំក្នុងថ្ងៃនេះ ហើយព្រះអង្គទ្រង់ត្រាស់បញ្ជាឱ្យពួកយើងខ្ញុំនាំយកសត្វចៀម និងពពែចំនួនមួយរយក្បាលចូលទៅក្នុងរាជធានីនាវេលារសៀលនៅឯង" ព្រះសិទ្ធត្ថទ្រង់មានព្រះបន្ទូលថា "បើអ៊ីចឹងអាត្មានឹងទៅជាមួយអ្នកដែរ" ។ ព្រះអង្គទ្រង់បីអោបកូនចៀមតូចនេះទៅរហូតដល់រាជធានី ។

៩៦- ទ្រង់និមន្តយាងតាមពីក្រោយហ្វូងចៀមពពែតាំងនោះ ព្រះសិទ្ធត្ថក៏ទ្រង់យាងមករាជធានីរួចព្រះអង្គទ្រង់យាងសំដៅទៅកាន់ព្រះបរមរាជវាំងជាកន្លែងដែលគេកំពុងតែប្រារព្ធធ្វើពិធីបូជាយញ្ញ ។ ព្រះរាជាព្រមទាំងបព្វជិតមួយក្រុមដែលជាអ្នកកាន់ជំនឿគោរពបូជាព្រះអគ្គីកំពុងនាំគ្នាសូត្រធម៌ថ្វាយព្រះអាទិទេពនៅខណៈដែលគេដុតភ្លើងឱ្យឆេះឡើងសន្ធោសន្ធៅនៅកន្លែងយញ្ញពិធី ។ អ្នកទាំងនោះហៀបនឹងសំលាប់សត្វចៀមបូជាទៅហើយ ប៉ុន្តែនៅពេលដែលគណៈអធិបតីនៃក្រុមជាអ្នកបូជាព្រះអគ្គី លើកដាវយ៉ាងមុតដើម្បីកាត់ក្បាលចៀមមួយជាដំបូងគេ ស្រាប់តែព្រះសិទ្ធត្ថមហាករុណាទិគុណទ្រង់ក្រោកឡើងយ៉ាងរហ័សរួចទ្រង់ឃាត់អ្នកសំលាប់ ។

(តទៅលេខក្រោយ)

- Original Illuatration and Naration in Thai by Gunapayuta.
- Translation into English by A Lu.
- Coloring by Yann Fang Lee
- Translation into Khmer by Bhikkhu Kong Am.

94- One day Siddhartha left Rajagrha to go to the food of the mountain where many hermits and sages dwelt. On the way, he saw dust falling down from the mountain amidst the pounding sound of animal hoofs. Going closer, he found a large flock of sheep and goats moving along like a bank of clouds. They were being helplessly driven toward the city. At the rear of the flock, a little lamb was straggling, limping along painfully, its leg wounded and bleeding. Siddhartha noticed the little lamb and its mother walking in front of it constantly looking back in deep concern for her offspring. His heart was filled with pity.

95- So Siddhartha took the little lamb with the wounded leg up into his arms, gently fondling it while walking along behind the flock. When he saw the shepherds, he asked: "Where are you driving this herd to? They should normally be driven back in the evening! Why do you drive them back at noontime?" The shepherds replied: "The King is holding a big sacrifice today, and we have been ordered to bring one hundred sheep and goats each to the city at noontime." Siddhartha said: "I'll go with you." He carried the little lamb in his arms all the way to the city.

96- Walking behind the flock of sheep, Siddhartha the reached the city; then he went toward the palace, where the sacrifice was being held. The King and a group of priests of the fire-worshipping cult were chanting hymns, while a big fire was bumming on the altar. They were about to kill the flock of sheep as a sacrifice, but when the leader of the fire-worshippers raised his sword to sever the head of the first sheep, Siddhartha quickly moved up and stopped him. ***(Continued After Issue)***

បណ្ណជាវកាសែតខ្មែរប៉ុស្តិ៍

ឈ្មោះ និងអាស័យដ្ឋានរបស់

ឈ្មោះ :..

អាស័យដ្ឋាន : ....

ខ្ញុំចង់ជាវ :

☐ កាសែតខ្មែរប៉ុស្តិ៍ ១ខែ មាន២លេខ ៦ខែ $30 ១២ខែ $60 ឬ $70 អឺរ៉ូ សម្រាប់អឺរ៉ុប
☐ សៀវភៅឈ្មោះ ....តម្លៃ $..................
☐ ស៊ីឌីប្រវត្តិសាស្ត្រខ្មែរ ៤ ម៉ោង តម្លៃមួយសិត $30
ខ្ញុំភ្ជាប់សែក ឬ មនីអដ័រ មក U.A.M.G តម្លៃ $..................
ផ្ញើមក U.A.M.G 438 LINDLEY AVE. PHILADELPHIA, PA 19120

Phone : 267-253-3947

Sav-Mor PHARMACY Tel: 215-467-1220

ឱសថស្ថានខ្មែរ

Sav-Mor PHARMACY

Sam EA R.Ph.
2232 S. 7th. (7th & Wolf) Philadelphia, PA 19148
Tell: (215) 467-1220 Fax: (215) 467-1447

បំរើលោកអ្នកដោយមិត្តភាព និងឆាន់ចិត្ត

- Sav Mor គឺជាឱសថស្ថានបំរើការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំតាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
- យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត់សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ និងអន្តរជាតិ
- ccept most insurance plans including Medicare & Medecaid
- Easy Prescription transfer
- Inside. Prepaid phone card. Call Cambodia.

ទស្សន៍ទាយជោគតារាសី

ជោគជតារាសីលោកអ្នក ថ្ងៃទី០៥ - ១៥ តុលា ឆ្នាំ២០១០

ឆ្នាំជូត : (ពពួកទេវតាប្រុស ធាតុទឹក)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ក៏អាចទទួលផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ លោកអ្នកអាចបណ្ដាក់ទុនរកស៊ីឬក៏ចេញទៅជួញដូរផ្លូវឆ្ងាយ មិនថាផ្លូវគោក ឬផ្លូវទឹកឡើយ គឺសមប្រកបតែទាំងអស់៕

ឆ្នាំឆ្លូវ : (ពពួកមនុស្សប្រុស ធាតុដី)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ថ្វីត្បិតតែមានភោគផលចំណូលហូរចូលច្រើនគួរសមក្ដី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ហើយក៏មិនខុសពីទូកធំក្ដោងធំនោះដែរ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះទាល់តែចេះអត់ឱនឲ្យគ្នាទើបមិនអាចប្រេះឆាគ្នាបាន ៕

ឆ្នាំខាល : (ពពួកយក្សស្រី ធាតុឈើ)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងឈ្លោះវិវាទកើតឡើង ចូរចេះអត់ធ្មត់ និងរំងាប់ចិត្តឲ្យបានត្រជាក់ ។ ចំពោះស្ត្រីភេទក្នុងរយៈពេលនេះមិនត្រូវនិយាយស្ដីប៉ប៉ាច់ប៉ប៉ោចឥតបានការច្រើនពេកទេ ព្រោះរឿងរ៉ាវផ្សេងៗអាចកើតចេញពីពាក្យសម្ដី ។ ក្នុងរយៈពេលនេះដែរ ចំពោះគូស្វាមីភរិយា ចូរប្រយ័ត្នប្រយែងក្រែងមានអ្នកទីបីចូលជ្រៀត ជ្រែកនៅគ្រួសារ ៕

ឆ្នាំថោះ : (ពពួកមនុស្សស្រី ធាតុឈើ)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះលោកអ្នកត្រូវរវៀសរវៃញាប់ជើងញាប់ដៃបន្តិច តែចូរកុំមានចិត្តលោភលន់ដោយចង់មានចង់បានឲ្យហួសប្រមាណពេកទេ ប្រយ័ត្នបែរជាកើតរឿងរ៉ាវអាចបង់ខាតលាភសក្ការៈវិញ ។ ចំពោះគូស្វាមីភរិយាក្នុងរយៈពេល នេះមានសុភមង្គលល្អណាស់នៅក្នុងគ្រួសារ ៕

ឆ្នាំរោង : (ពពួកទេវតាប្រុស ធាតុមាស)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះបើមានរឿងជម្លោះកើតឡើង ចូរចេះអត់ធ្មត់ និងរំងាប់ចិត្តឲ្យបានត្រជាក់ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់នឹងកំហល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ចំពោះគូស្វាមីភរិយាក្នុងរយៈពេលនេះ ចូរប្រយ័ត្នប្រយែងក្រែងមានអ្នកក្រៅមកញុះញង់ ៕

ឆ្នាំម្សាញ់ : (ពពួកមនុស្សប្រុស ធាតុភ្លើង)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ទោះបីជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ចូរកុំធ្វើប្រហែសឲ្យសោះ ជាពិសេសចំពោះអាជីវករ អ្នករកស៊ីជួញដូរមុននឹងទទួល ឬប្រគល់នូវមុខទំនិញសព្វសារពើ ចូរចេះពិនិត្យមើលគុណភាព និងរាប់ចំនួនឲ្យបានត្រឹមត្រូវទើបមិនចាញ់បោកគេ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះមានភាពស្និទ្ធស្នាលដូចប្រក្រតី៕

ឆ្នាំមមី : (ពពួកទេវតាស្រី ធាតុភ្លើង)

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់។ លោកអ្នកអាចបណ្ដាក់ទុនរកស៊ី ឬក៏ចេញទៅជួញដូរផ្លូវឆ្ងាយ និងថាផ្លូវគោក ឬផ្លូវទឹកឡើយ គឺសមប្រកបតែទាំងអស់ ព្រោះអាចរកផលកម្រៃបានច្រើនត្រឡប់ចូលផ្ទះ៕

ឆ្នាំមមែ : (ពពួកទេវតាស្រី ធាតុមាស)

រាសីលោកអ្នកល្អមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ចូរកុំធ្វេសប្រហែសឲ្យសោះ ជាពិសេសមុនពេលចុះហត្ថលេខា ឬផ្ដិតមេដៃលើលិខិតស្នាមផ្សេងៗ ចូរពិនិត្យល្អិតល្អន់ប្រយ័ត្នបង់ខាតទ្រព្យច្រើន ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះទាល់តែចេះអត់ឱនឲ្យគ្នាទៅវិញទៅមក ទើបទទួលបានសេចក្ដីសុខ ៕

ឆ្នាំវក : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាស្មុគស្មាញច្រើន ។ ក្នុងរយៈពេលនេះ អ្វីដែលលោកអ្នកត្រូវយកចិត្តទុកដាក់នោះ គឺនៅពេលទូទាត់បញ្ជីប្រាក់កាសផ្សេងៗ ចូរប្រយ័ត្នប្រយែងក្រែងមានការភ្លាំងភ្លាត់ អាចបង់ខាតទ្រព្យច្រើន និងអាចកើតមានរឿងក្ដីក្ដាំទៀតផង ។ ចំពោះអាជីវករអ្នករកស៊ីប្ដូរប្រាក់ ឬលក់គ្រឿងអលង្ការផ្សេងៗ ចូរមានការប្រយ័ត្នប្រយែងក្រែងមានជនខិលខូចលួច បន្លំភ្នែកស្រស់ៗ ៕

ឆ្នាំរកា : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកល្អធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែលោកអ្នកអាចរកផលចំណូលបានច្រើនគួរសមក្ដី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក គឺបានត្រឹមតែចំណាយកម្លាំង និងពេលវេលាឥតអំពើតែប៉ុណ្ណោះ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ បើស្រលាញ់កុំទៅញឹក បើរលឹកកុំទៅញយ ទើបចំណងស្នេហ៍អាចគង់វង្សបានយូរអង្វែង ៕

ឆ្នាំច : (ពពួកយក្សស្រី ធាតុដី)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ លោកអ្នកមានអារម្មណ៍ភ្លឺថ្លាគំនិតប្រាជ្ញាឈ្លាសវៃ បើបានជួបពិគ្រោះពិភាក្សាការងាររកស៊ី និងចាប់និយាយត្រូវរ៉ូវ និងមានការចុះសម្រុងនឹងគ្នា ។ ចំពោះ អាជីវករមានមានទំនិញលក់ចេញទិញ ចូលឥតទំនេរដៃ ព្រមទាំងមានភោគផលកម្រៃហូរចូលច្រើនទៀតផង៕

ឆ្នាំកុរ : (ពពួកមនុស្សស្រី ធាតុទឹក)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាលំបាកៗច្រើន ។ ក្នុងរយៈពេលនេះ ចូរកុំធ្វេសប្រហែសឲ្យសោះ ជាពិសេសចំពោះកម្មករសំណង់ដែល ប្រកបការងារនៅតាមទីខ្ពស់ទាប ចូរប្រយ័ត្នប្រយែងក្រែងជួបគ្រោះថ្នាក់ធ្លាក់ពីទីខ្ពស់ នាំឲ្យរងរបួសធ្ងន់ស្រាល ហើយអាចឈានដល់ការរលត់សង្ខារទៀតផង ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ មិនត្រូវចាប់ត្រចៀកទន់ជឿសម្ដីញុះញង់របស់អ្នកផ្សេងឡើយ ទើបបានសុខសប្បាយចិត្ត ៕

សោភ័ណភាព

ប្រើផ្លែឈើជួយបង្ហាប់ រន្ធរោមមុខ

សំរាប់សុភាពស្ត្រីដែលមានស្បែកមុខមិនរលីង ព្រោះតែមានរន្ធរោមរាងរីកធំនោះ សូមកុំទាន់កើតកង្វល់ ព្រោះនៅមានបន្លែផ្លែឈើច្រើនមុខណាស់ដែលអាចជួយបង្ហាប់រន្ធរោមនៅលើផ្ទៃមុខបាន ។ វិធីមានដូចខាងក្រោមនេះ៖

ប្រសិនបើនៅក្នុងផ្ទះមានចេកអំបូង ត្រសក់ ប៉េងប៉ោះ អាចជ្រើសរើសយកមួយណា ក៏បានមកចិត ឬបកសំបករួចខ្វេះគ្រាប់ចេញឲ្យអស់ រួចហាន់វាជាចំណិតតូចៗ ។ បន្ទាប់មកយកវត្ថុធាតុដើមទាំងអស់នោះទៅក្រឡុកនៅក្នុងម៉ាស៊ីនក្រឡុក ដោយកុំភ្លេចចាក់ទឹកដោះគោជូរ ឬទឹកឃ្មុំចូលលាយបន្តិច (អាចជ្រើសរើសប្រើមួយណាក៏បាន) ។ បន្តការក្រឡុករហូតដល់ក្លាយទៅជាក្រែមមួយខាប់ រួចយកមកលាបបំពោកនៅលើស្បែកមុខ ហើយនិង.ក ទុកចោលរយៈពេល១៥នាទី ទើបប្រើទឹកក្ដៅឧណ្ហៗលាងសំអាតចេញ ។ រូបមន្តមួយនេះក្រៅពីជួយឲ្យរន្ធរោមនៅលើស្បែកមុខបានហាប់ណែន រហូតដល់ស្បែកមានសភាពរលីងហើយនោះ វាថែមទាំងជួយសំអាតស្បែកមុខជួយបង្កើនសំណើមឲ្យស្បែកទៀតផង ៕

សម រង្ស៊ី : បើគ្មានថ្ងៃ២៣ តុលាទេ កម្ពុជានឹងក្លាយទៅជាខេត្តរបស់យួន

ដោយ : ពេជ្រ បណ្ឌូល

October 23, 2010 12:46 PM/Free Press Magazine

ថ្លែងទៅកាន់អ្នកចូលរួម ដែលមានតំណាងអង្គទូតមួយចំនួនប្រចាំប្រទេសកម្ពុជា អ្នកតំណាងរាស្ត្រមកពីគណបក្សសិទ្ធិមនុស្ស និងអ្នកគាំទ្ររបស់គណបក្សប្រឆាំងនេះ ប្រមាណជាពាររយនាក់តាមរយៈ វីដេអូ ខនហ្វិរិន ពីទីក្រុងប៉ារីស នៅព្រឹកថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១០ ដែលជាខួបលើកទី១៩ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស លោក សម រង្ស៊ី បានលើកឡើងថា "បើពុំមានថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ទេ នោះប្រទេសកម្ពុជានឹងក្លាយទៅជាខេត្តរបស់យួន ។ ហើយយុទ្ធនាការដែលនាំឱ្យមានកាសសម្លាប់មនុស្សតាមរយៈរបស់ដែលគេហៅថា ក៥ ឬ ក៦ នោះក៏ពុំទាន់ត្រូវបានបញ្ចប់ពីកម្ពុជាដែរ ៕

សម រង្ស៊ី ជាមួយបាតុករក្រុងប៉ារីស

ពេជ្រ បណ្ឌូល

ឈប់បារម្ភទៅចំពោះជំងឺឬសដូងបាត

សូមលោកអ្នកកុំព្រួយបារម្ភទៀតឱ្យសោះចំពោះជំងឺឬសដូងបាតនេះ! លោកអ្នកមានជំងឺឬសដូងក្នុងឬ? (Internal Hemorroid) ឬក៏ឬសដូងក្រៅ?(ExternalHemorroid) មិនជាបញ្ហាធំពេកទេ តែកុំទុកឱ្យហួសពេលឱ្យសោះ វាអាចក្លាយទៅជាជំងឺមហារីក ពោះវៀនធំ ។ គ្មានការវះកាត់ឬដុត គ្មានការលាបថ្នាំ បង្កាត់នាំឱ្យមានដំបៅ គ្មានការចាក់ថ្នាំចំកន្លែងឬសដូងបាតនោះនាំឱ្យហើមរលួយដើម្បីឱ្យឬសដូងបាតជ្រុះចេញនោះទេ! ។ នេះជាថ្នាំបុរាណជប៉ុន គ្រាន់តែលេបថ្នាំអាចធ្វើឱ្យឬសដូងក្នុងក្ដី ឬឬសដូងក្រៅក្ដីរួញតូចបាត់ទៅ ។ ការធ្លាក់ឈាម ឈឺចុកចាប់ ក្រហល់ក្រហាយរមាស់ទ្វារលាមកឈាមរុំលាមក បត់ជើងលំបាក ។ល ។ នឹងបាត់សូន្យទៅ ។ សូមទាក់ទងនឹងលោកគ្រូពេទ្យធ្លាប់មានពិសោធន៍

KIM, Phien 421 E Mentor St. Philadelphia. PA 19120
Phone : **215 680 2059**

(Continued from page 01)

Pipe Bomb scared in Lynn....

The second explosion happened on October 13 where a Saturn made car parked in front of a 3 décor apartment of 3 Essex Street found exploded at about 10:20 pm. The woman who lives on the first floor said her husband is the owner of 3 Essex property. She did not want to be identify, but did confirmed that there was an explosive device blew out the car in front of her apartment. According to Lynn Daily Item, the car belong to the family who live on the 3rd floor of 3 Essex street and that Lynn Fire Dept. Arson investigator, Dave Legere believed the couple in this apartment were "possible target".

Ms. Dany Ouk, one of the family business owners on Essex Street reported she learned of the bomb incident from reading the Lynn Daily Item and watching Fox News from 2 weeks ago. She also reported her Cambodian customers did not seem to be aware of the bomb incidents.

The third bomb incidents generated panic and nervousness for the neighbors and homeowner of 80 Collins Street who discovered the pipe bomb attached to his propane gas grill on October 16. This was when the neighborhood was being evacuated. The fourth scar happened on October 18 at Red Rock Park when passersby spotted a knapsack that appeared to contain an explosive device. The bomb-disarming experts were again being called. According to the Lynn Daily Item, police found a "bottle of vodka and orange juice mixer" inside the backpack that said to belong to an intoxicated man.

Ms. Por, a mother of 4 boys said, "Cambodian parents should pay attention to this kind of incidents and the areas where it happened in their community, so that they can warn their children to keep out of harms way."

According to The Daily Item reporter, David Liscio, "a task force comprised of Lynn and Swampscott police and fire investigators, state troopers and federal agents from the FBI and the Bureau of Alcohol, Tobacco, Firearms and Explosives (ATF) have narrowed the search to a handful suspects." Police Chief Kevin Coppinger released a statement on October 19, per Liscio's report stated, "There are a number of persons of interest who we have been talking to. The evidence collected is being analyzed at the State Police crime lab." He also noted that "detectives are awaiting the results."

តមកទំព័រទី ០១

ទស្សនកិច្ចរបស់អគ្គលេខាធិការនៃអង្គការ...

បានហើយ បើចង់បន្តទៅទៀត សូមប្រគល់រឿងនេះមកតុលាការខ្មែរទៅវិញ ។

*ចំពោះដំណើរការការិយាល័យនៃ អ.ស.ប នៅកម្ពុជាសម្រាប់សិទ្ធិមនុស្ស លោក ខៀវ កាញារីទ្ធ បាននាំពាក្យរបស់ជំនួបកំពូលនោះថា កម្ពុជាសម្រេចថា ការិយាល័យត្រូវតែបិទយ៉ាងយូរណាស់នៅឆ្នាំ ២០១១ ចំណែកឯកនាយកនៃការិយាល័យនោះ គឺលោក គ្រីស្តូហ្វ ប៉េស៊ូ ត្រូវតែដកចេញភ្លាម ពីព្រោះមន្ត្រី អ.ស.ប នោះមិនដែលបានមកធ្វើការពិគ្រោះជាមួយនឹងរដ្ឋាភិបាលទេ កន្លងមកច្រើននាំពាក្យរបស់គណបក្សប្រឆាំង ។

*ចំពោះតួនាទីនៃ អ.ស.ប ក្នុងជម្លោះខ្មែរ-ថៃ នៅ តំបន់ព្រះវិហារ លោក ហ៊ុន សែន សុំឱ្យ អ.ស.ប ជួយណែនាំឱ្យថៃដកទ័ពថយទៅចំណុចដើមមុនពេលកើតទំនាស់ ម្យ៉ាងទៀត អ.ស.ប អាចធ្វើអន្តរាគមន៍ប្រសិនបើមានការផ្ទុះអាវុធពីកងទ័ពក្នុងទ្រង់ទ្រាយធំ... ។ល ។

គួររំលឹកថា នៅពេលទស្សនកិច្ចរបស់លោក បាន គីមូន នោះមានបាតុករមួយចំនួន បានប៉ុនប៉ងធ្វើញត្តិជូនលោកអគ្គលេខាធិការនៃ អ.ស.ប សុំឱ្យជួយពួកគេដើម្បីលក់ដីធ្លីដែលរដ្ឋាភិបាល បានរឹងអូសនោះយកមកវិញ ក៏ប៉ុន្តែត្រូវបានក្រុមប៉ូលិសបង្ក្រាបបណ្តាលឱ្យមានរបួស និងចាប់ខ្លួនបាតុករខ្លះ ។ មន្ត្រីនៃ អ.ស.ប បាននិយាយថា លិខិតដែលជាញត្តិជូនលោក បាន គីមូន បានទទួលហើយ និងបញ្ជូនទៅលោកអគ្គលេខាធិការរួចហើយ រីឯអ្នកត្រូវគេចាប់ខ្លួននោះក៏ត្រូវបានធ្វើអន្តរាគមន៍ឱ្យចេញពីការឃុំឃាំងរួចហើយដែរ ។ មន្ត្រីសិទ្ធិមនុស្សនៃ អ.ស.ប និងអង្គការក្រៅរដ្ឋាភិបាលបានថ្លែងថា "ទង្វើចំពោះបាតុករដែលសំដែងការមិនសប្បាយចិត្ត ដោយសន្តិភាពបានត្រូវទទួលការបង្ក្រាបរបៀតនេះ គឺជាអំពើរំលោភសិទ្ធិមនុស្សរបស់ក្រុមអាជ្ញាធរ ៕

តមកទំព័រទី ០១

លោកស្រីរដ្ឋលេខាធិការក្រសួងបរទេស...

ធនធានមនុស្សសម្រាប់បំរើការក្នុងការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា" ។

ទាក់ទងទៅនឹងការចង់បិទការិយាល័យសិទ្ធិមនុស្សរបស់ អ.ស.ប នៅកម្ពុជា លោកស្រី ហ៊ុឡារី បាននិយាយថា ការិយាល័យនេះ មានសារៈសំខាន់ណាស់នឹងដំណើរការជាបន្តទៅទៀត ដោយមានសហការណ៍ជារដ្ឋាភិបាលកម្ពុជា ។ ចំពោះរឿងបំណុលដែលប្រទេសកម្ពុជា ក្នុងរបបសាធារណរដ្ឋខ្មែរ បានជំពាក់សហរដ្ឋអាមេរិកនោះ លោកស្រីនឹងបញ្ជូននូវអ្នកជំនាញការអាមេរិកាំង មកជជែកគ្នាជាមួយនឹងកម្ពុជា មុននឹងសម្រេចថា ត្រូវលុបចោលទាំងស្រុងឬក៏ត្រូវបង្វែជាជំនួយអភិវឌ្ឍន៍កម្ពុជាទៅវិញ ។ រីឯបញ្ហាតុលាការខ្មែរក្រហម លោកស្រី ហ៊ុឡារី គ្លីនតុន បន្ថែមថា លោកស្រីនឹងស្នើឱ្យសហរដ្ឋអាមេរិក ផ្តល់ជំនួយបន្ថែមដល់តុលាការខ្មែរក្រហម ឱ្យអាចដំណើរការកាត់ទោសក្នុងសំណុំរឿង០០២ឱ្យបាននៅឆ្នាំ២០១១នេះ ។

លោកស្រី ហ៊ុលឡារី បានថ្លែងនៅចំពោះសមាជិកសភានៃគណបក្សប្រឆាំង ដែលមាគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ថា លោកស្រីនឹងប្រឹងប្រែងក្នុងការធ្វើអន្តរាគមន៍ឱ្យលោក សម រង្ស៊ី អាចប្រឡប់មកធ្វើការនៅកម្ពុជាវិញបាន ពីព្រោះកម្ពុជាត្រូវការអ្នកដឹកនាំនៃគណបក្សប្រឆាំង ។

រដ្ឋលេខាធិការក្រសួងការបរទេសអាមេរិកាំងបានបញ្ចប់ដំណើរទស្សនកិច្ចនៅកម្ពុជា និយាយថា "នឹងខិតខំឱ្យអស់ពីសមត្ថភាព ដើម្បីធ្វើកិច្ចការជាមួយរាជរដ្ឋាភិបាលកម្ពុជា ហើយសង្ឃឹមថា ស.រ.អា នឹងក្លាយជាដៃគូ និងជាមិត្តភក្តិដ៏ល្អជាមួយកម្ពុជា ៕

APARTMENT FOR SALE

4 Apt Units on 3rd & Grant Ave.
Northeast Phila, PA

Each/1 Bed, 1 Bath, Living room & Kitchen . Currently occupied. Generate Immediate Income.

Asking Price $230.000.
Contact: 267-242-5428

Cargo *plus* East LLC.

លោកអ្នកចង់ផ្ញើអីវ៉ាន់ទៅភ្នំពេញ

យើងធានាថា ទំនិញលោកអ្នក នឹងផ្ញើទៅដល់ទីដៅ១០០% យើងយកទំនិញដោយផ្ទាល់ដៃទៅដល់មាត់ទ្វារផ្ទះ នៅគ្រប់កន្លែងនៃភ្នំពេញ យើងមានបទបញ្ជាថា "គ្មានយកកំរៃបន្ថែមណាផ្សេង" ទៀតទេ ប្រអប់ផ្ញើរបស់លោកអ្នកនឹងទៅដល់កន្លែងក្នុងកំណត់ ៥៥ថ្ងៃ យើងបញ្ជូនទំនិញចេញទៅភ្នំពេញរៀងរាល់សប្តាហ៍

តម្លៃ 175 $

តាមប្រអប់ទំហំ ***21"x21"x33"*** គ្មានកំណត់ទម្ងន់

For more details, call Toll Free No: 1877-463-6217
OR KENT (267) 240-9532
Email:kkent747@yahoo.com

IN WICHTA FALLS TEXAS

មានហាង LIQUOR នៅរដ្ឋ TEXAS ត្រូវការលក់ទាំងអគារទាំងដីរួមទាំងកន្លែងលាងឡានមួយទៀតផង ក្នុងតម្លៃ $690.000 (អាចនិយាយតម្លៃគ្នាបាន)

Excellent location, including land.
Liquor business (1,500 square feet), and new car wash.
Big Corner lot, good visibility, additional building can be added.
Drive through, short hour Check cashing/lottery/western union
Take home $14,000 per month income
Asking $690,000+inventory (negotiable)

Please Call Rick : 940-337-7633 (Cell), 940-687-9988 (Store)

ផ្ទះ Duplex តម្លៃ $80.000

នៅជ្រុងផ្លូវ 12Th st. និង Ruscomb st.
North Philadelphia
ផ្ទះធ្វើរួចហើយ, បង្កួចថ្មី,
ចង្ក្រានបាយ និងដំបូល
រៀបជាបន្ទប់ អាចនៅបានបីគ្រួសារ
ឥឡូវនេះមានពីរគ្រួសាររស់នៅ,
ដែលបង្កើតប្រាក់ចំណូលបានភ្លាម

ទូរស័ព្ទ : ពៅ ឆាយ 267-258-6841

AUTO GARAGE FOR SALE

HASS´S AUTO ជួសជុលតួឡានដែលបុកគ្នាម្ចាស់ហាងចូលនិវត្តន៍ -ហាងមានដំណើរការ១៧ឆ្នាំមកហើយ -ពាណិជ្ជកម្មមានលំនឹងល្អគ្រប់រដូវលោកអ្នកអាចទិញតែពាណិជ្ជកម្មក៏បាន -ទិញដីជាមួយនឹងផ្ទះក៏បាន -ទិញទាំងពីររួមគ្នាក៏បាន បើចង់ដឹងច្បាស់
សូមទូរស័ព្ទរកឈ្មោះ "នីក"

17 years well established business.

Please Call Nick : 267-242-7938 For Showing

ការិយាល័យច្បាប់របស់មេធាវី
អេមេត ម៉ាឌិន

LAW OFFICES OF R. EMMETT MADDEN, ESQUIRE

ការពារករណីឧក្រិដ្ឋ

- ✓ បញ្ហាធ្វើតាក់
- ✓ បញ្ហាជាមួយមន្ត្រីពន្ធដារ
- ✓ បើកបរនៅពេលស្រវឹងស្រា ឬគ្រឿងញៀន
- ✓ រំលោភរូបរាងកាយ
- ✓ ចាប់ខ្លួនដោយលក់ ឬប្រើគ្រឿងញៀន
- ✓ ក្លែងបន្លំធានារ៉ាប់រង
- ✓ ការដកហូតអាជ្ញាប័ណ្ណ
- ✓ ករណីអន្តោប្រវេសន៍

របួសលើរាងកាយ

- ✓ គ្រោះថ្នាក់រថយន្ត
- ✓ ព្យាបាលជម្ងឺមិនត្រឹមត្រូវ
- ✓ រអិលដួល
- ✓ របួសដោយឆ្កែខាំ
- ✓ គ្រោះថ្នាក់ឡានធំ
- ✓ គ្រោះថ្នាក់កង់ម៉ូតូ
- ✓ គ្រោះថ្នាក់ផ្នែកខួរក្បាល

ពួកយើងមានបុគ្គលិកនិយាយភាសាខ្មែរ

CALL 215-884-9300
www.thephillylawers.com

SAIGON PLAZA

ជាហាងថ្មីស្រឡាង ស្ថិតនៅញូជើស៊ីខាងត្បូង-យើងមានរបស់
គ្រប់យ៉ាងដែលលោកអ្នកត្រូវការ នៅមិនឆ្ងាយពីផ្ទះ

新城超級市場
SUNSENG SUPERMARKET
5201 Kaighns Ave (Route 38 W) Pennsauken, NJ 08109
Tel : (856) 663-2238

- ▸ បន្លែបង្គាស្រស់ៗមកពីចំការ
- ▸ គ្រឿងសមុទ្រ -ត្រីរស់គ្រប់យ៉ាងដែលលោកអ្នកចូលចិត្ត
- ▸ សាច់ : មានសាច់គ្រប់មុខ សាច់ជ្រូក-មាន់-គោ-ចៀម... ។ល ។

- ▸ នៅបរិវេណប្លាហ្សា មានពាណិជ្ជកម្មផ្សេងៗទៀត ដូចជា : កាហ្វេ ទូឡាន -ហ្វើ៣៨- ABC ប្តូរលុយ -លក់សំបុត្រយន្តហោះ មានហាងកាត់ និងអ៊ុតសក់ -JB ក្រុមហ៊ុនអាស៊ាន -ក្រុមហ៊ុនធ្វើតាក់ពន្ធដារ
- ▸ បើកទ្វារមួយអាទិត្យ : ៧ថ្ងៃ ពីម៉ោង 8:00 AM ដល់ 9:00 PM
- ▸ បុគ្គលិកនៅបំរើយ៉ាងរាក់ទាក់ ដើម្បីបំពេញបំណងលោកអ្នក
- ▸ យើងទទួល Credit Card -Food Stamp-EBT- Family Card

នៅមានបន្ទប់
សំរាប់ធ្វើការិយាល័យ
សំរាប់ជួល

HONG KONG
Super Market

FAMER´S BEST

ON SALE PERIOD 11/05/10-11/11/10

HONG KONG SUPERMARKET (PA) WEEKLY PROMOTION ITEMS

3LB for $1.00

3LB for $1.00

3LB for $1.00

$0.49 per LB

3LB for $1.00

3LB for $1.00

4 for $1.00

7 for $1.00

$0.79 per LB

$7.99 per BOX

$0.69 per LB

$2.19 per LB

$1.89 per LB

$6.99 per Box

$2.69 per bag

2LB for $9.99

$2.99 per LB

$4.99 per LB

$5.99 per LB

$2.49 per Bag

$1.49 per BLT

$2.49 per BLT

$2.99 per BLT

$1.99 per Can

$3.99 per Box

$3.49 per Can

$6.99 per Bag

571 ADAMS AVE.PHILADELPHIA,
PA 19120 Tel : 215-7281300 Fax : 215-728-1600

- ចំណាយ $140 ដុល្លារ ទទួលបានអង្ករស្រូវស 25 ផោន
- ចំណាយ $100 ដុល្លារ ទទួលបានទូរភេសជ្ជៈ ឬមីកញ្ចប់មួយប្រអប់ (តម្លៃ 8.99)
- ចំណាយ $25 ដុល្លារ ទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។

OPEN 7DAY
8:00-9:00

ឥតយកថ្លៃ
លើ
វីតាមីន

ឥតយកថ្លៃ
លើ
ថ្នាំចាក់ ឬលេបបង្ការជម្ងឺ

ឥតយកថ្លៃលើ
យកវេជ្ជបញ្ជាទៅទិញថ្នាំ
និងបញ្ជូនថ្នាំមកវិញដល់ផ្ទះ

Rx EZ PHARMACY

INTRODUCING THE MOST COST EFFECTIVE PLAN
FOR SELECTED GENERIC DRUGS

$3.99
ថ្នាំសម្រាប់ប្រើ30ថ្ងៃ

$12.99
ថ្នាំសម្រាប់ប្រើ90ថ្ងៃ

215-728-6300
Bela M. Patel
Pharmacist

Hours: M-F 9-7, Sat 10-3, Sun Closed
1701 Cottman Ave. Philadelphia, PA 19111

តមកទំព័រទី ០៥

កិច្ចសម្ភាសន៍រវាងខ្មែរប៉ុស្តិ៍ជាមួយប្រធានសមាគម...

សិរិទ្ធ ប៉ែន : បាទខ្ញុំសូមជម្រាបថា មិនថាអតីតជំនាន់ៗណាទេ ឱ្យតែជាអតីតយុទ្ធជន គឺយើងទទួលយកទាំងអស់ និងទី២ គឺយើងចង់រៀបចំ Next goneration មានការធ្វើជាមួយអតីតយុទ្ធជន ហើយក៏ឱ្យពួកគាត់បានរៀនសូត្រ ដូចជាបញ្ជូនទៅរៀនផ្នែកកងទ័ពរបស់សហរដ្ឋអាមេរិក។

ស្តាប់ការបរិយាយរបស់លោក ថាច់ ម៉ារិន វិញម្តង

"ខ្មែរប៉ុស្តិ៍"បានជួបសម្ភាសន៍តាមទូរស័ព្ទជាមួយលោក ថាច់ ម៉ារិន ដែលលោកមានឋានន្តរស័ក្តជាវរៈសេនីយ៍ឯក កាលពីថ្ងៃទី៣១ ខែតុលា កន្លងមកនេះជុំវិញរឿងក្រុមអតីតយុទ្ធជន ដែលត្រូវបានបំបែកជាពីរក្រុមនេះ។ លោក ម៉ារិន បានថ្លែងថា "ការបង្កើតសមាគមអតីតយុទ្ធជនរបស់លោក សិរិទ្ធ ប៉ែន គឺលោកគ្មានយល់ជំទាស់អ្វីឡើយ.ព្រោះនោះ ជាសិទ្ធិសេរីភាពនៃបុគ្គលម្នាក់ៗក្នុងការសម្រេចធ្វើអ្វីមួយ"។ ប៉ុន្តែលោក ម៉ារិន បានសង្កត់ធ្ងន់ថា "ចំពោះការធ្វើអ្វីមួយដោយខុសច្បាប់ គឺអាចប្រឈមមុខជាមួយនឹងបញ្ហាផ្លូវច្បាប់បាន"។ ការនិយាយបែបនេះ ត្រូវបានគេកាត់យល់ថា ទំនងជាចង់ដាស់តឿនក្រើនរំលឹកដល់ក្រុមលោក សិរិទ្ធ ប៉ែន កុំឱ្យធ្វើនូវអ្វីដែលប្រាសចាកពីច្បាប់របស់រដ្ឋាភិបាលសហរដ្ឋអាមេរិកតែប៉ុណ្ណោះ។

ដោយឡែកក្នុងខណៈដែលលោកបារ៉ាក់ អូបាម៉ា អញ្ជើញមកកាន់ទីក្រុងហ្វីឡាដែលហ្វៀ កាលពីថ្ងៃទី១០ ខែតុលា កន្លងមកនេះ ក្រុមអតីតយុទ្ធជន USV-JSC ដែលដឹកនាំដោយ លោក ថាច់ ម៉ារិន មួយនេះក៏មានឱកាសជួបជាមួយលោក អូបាម៉ា នៅក្នុងបន្ទប់ VIP ផងដែរ ។ លោក ម៉ារិន បានប្រាប់"ខ្មែរប៉ុស្តិ៍"ថា ពួកយើងមិនដាក់ជាសំណើរឬក៏សុំក្នុងផ្នែកណាមួយដល់លោក អូបាម៉ា ក្នុងជំនួបនោះឡើយ ដោយជំនួបនោះ គឺគ្រាន់តែជាការស្វាគមន៍ដល់លោកប្រធានាធិបតីតែប៉ុណ្ណោះ។

វរៈសេនីយ៍ឯក ថាច់ ម៉ារិន

ឆ្លើយតាមចំពោះសំណួរ"ខ្មែរប៉ុស្តិ៍"ជុំវិញការបំពាក់ស័ក្តិលោក ម៉ារិន បានបំភ្លឺថា "ចំពោះបញ្ហាស័ក្តិទាំងនោះ គឺយើងមិនចេះតែបំពាក់ឱ្យគ្នាដោយងាយៗឡើយ គឺត្រូវបានបំពាក់ដោយក្រសួងការពារជាតិអាមេរិក។

សូមជម្រាបថា សមាជិកនៃក្រុមអតីតយុទ្ធជន USV-JSC នេះត្រូវបានគេប្រទះឃើញរាល់សមាជិកម្នាក់ៗសុទ្ធសឹងតែមានឋានន្តរស័ក្តិធំៗចាប់តាំងពីថ្នាក់វរៈសេនីយ៍ឯក, វរៈសេនីយ៍ទោ, វរៈសេនីយ៍ត្រី, អនុសេនីយ៍ឯក និងថ្នាក់អនុសេនីយ៍ទោជាដើម។ ដោយឡែកព្រះសង្ឃពីរអង្គនាម ញឹម ណាក់ ក៏ត្រូវបានទទួលឋានន្តរស័ក្តិជាវរៈសេនីយ៍ឯក ។ ចំណែកឯកព្រះតេជគុណ អៀវ សុវណ្ណ ត្រូវបានទទួលឋានន្តរស័ក្តិជាអនុសេនីយ៍ឯកផងដែរ ៕

ពេទ្យថែរក្សាធ្មេញប្រចាំគ្រួសារ
FAMILY DENTAL CARE
AT
SMILE CARE CENTER
626 Snyder Avenue. Philadelphia, Pa 19148

យើងខ្ញុំអាចបកប្រែភាសាខ្មែរជូនលោកអ្នក សូមទាក់ទងជាមួយ ឈ្មោះ រ៉ន ហេង និងជា លែនតាវ ដើម្បីណាត់ពិនិត្យ

WE SPEAK CAMBODIAN. PLEASE CONTACT :
MALY CHHORN 215-391-4100

Children and Adults Welcome
- Exams
- Root Canals
- Extractions
- Cleanings
- Braces
- Dental Implants

We accept all types of insurance including Medicare & Medicaid
PLEASE CALL TO MAKE YOUR APPOINTMENT TODAY !
(215) 391-4100

យើងទទួលយកគ្រប់ប្រភេទ អ៊ិនស្វ៊ិន ដោយរាប់ទាំងម៉េឌីឃែ និងម៉េឌីឃេដ ផង សូមទូរស័ព្ទរកយើងខ្ញុំ នៅថ្ងៃនេះ ដើម្បីណាត់ពិនិត្យនូវលេខ (215) 391-4100

តើខ្ញុំអាចផ្ញើប្រាក់ទៅទូទាំងប្រទេសកម្ពុជា ក្នុងតម្លៃសេវាកម្មត្រឹមតែ $11.99[1] ?

បាទ!

- ផ្ញើប្រាក់ និងទទួលប្រាក់ត្រឹមតែប៉ុន្មាននាទីប៉ុណ្ណោះ[2]
- មានទីតាំងភ្នាក់ងារច្រើនជាង 190 កន្លែង[3] នៅទូទាំងប្រទេសកម្ពុជា
- ទូទាត់ជាប្រាក់ដុល្លារអាមេរិក[4]

WESTERN UNION | yes!

westernunion.com | 1-800-325-6000 | សេវាកម្មផ្ទេរប្រាក់

រក្សាសិទ្ធិគ្រប់យ៉ាងដោយ © 2010 WESTERN UNION HOLDINGS, INC. 1

---

1. បន្ថែមទៅលើកម្រៃឈ្នួលនៃការផ្ទេរប្រាក់ វេស្ទើន យូនៀន ក៏រកប្រាក់ចំណូលពីការប្តូរប្រាក់ដុល្លារ ទៅជារូបិយប័ណ្ណបរទេសផងដែរ។ កម្រៃឈ្នួលផ្សព្វផ្សាយ អាចមានទៅលើការផ្ទេរប្រាក់រហូតដល់ $500 ។កម្រៃឈ្នួលសេវាផ្ទេរប្រាក់ សម្រាប់ទីតាំងភ្នាក់ងារទូទាំងប្រទេស លើកលែងតែតំបន់ Stockton, Seattle និង Boston metro ។ 2. ទឹកប្រាក់អាចត្រូវបានពន្យារពេល ឬមិនមានសេវាកម្ម អាស្រ័យទៅលើល័ក្ខខ័ណ្ឌនៃប្រតិបត្តិការជាក់ស្តែង រួមទាំងចំនួនប្រាក់បញ្ញើប្រទេសដែលផ្ញើទៅ លទ្ធភាពរូបិយប័ណ្ណ បញ្ហានៃការត្រួតពិនិត្យ តម្រូវការអត្តសញ្ញាណកម្ម ម៉ោងនៅតាមទីតាំងភ្នាក់ងារ ភាពខុសគ្នានៃម៉ោងនៅតាមតំបន់ ឬការជ្រើសរើសជម្រើសនៃការពន្យារពេល។ ល័ក្ខខ័ណ្ឌបន្ថែមទៀតអាចត្រូវបានអនុវត្ត។ សូមមើលលើបែបបទផ្ញើប្រាក់ សម្រាប់ព័ត៌មានលម្អិត។ 3. បណ្តាញទិន្នន័យគិតត្រឹមថ្ងៃទី 31 ខែមីនា ឆ្នាំ 2010 ។ 4. អាស្រ័យទៅតាមទីតាំងភ្នាក់ងារដែលបានកំណត់ និងលទ្ធភាពនៃទីតាំងនោះតែប៉ុណ្ណោះ។